**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

## របបគតិយុត្តអនុវត្តចំពោះការគ្រប់គ្រងកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាក

ស្រាវជ្រាវពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយនិស្សិតៈ

**ភក់ ជីវី**

**គីម មីនយ្យូ**

សាស្ត្រាចារ្យណែនាំៈ

**លោក នី វិចិត្រ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

## សេចក្តីថ្លែងអំណរគុណ

ក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានធ្វើកាសិក្សាស្រាវជ្រាវ និងបានបញ្ចប់នូវរបាយការណ៍ជាស្ថាពរ ។ ក្នុងន័យនេះដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតចំពោះ៖

-**មាតាបិតា** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា ប្រៀនប្រដៅ និងទំនុកបម្រុង ព្រមទាំងផ្តល់ជាចំណេះដឹង និងផ្តល់ដំបូន្មានល្អៗ រហូតធ្វើឱ្យកូនបញ្ចប់ការសិក្សាដោយជោគជ័យ និងក្រេបយកចំណេះដឹងក្នុងនាមជាពលរដ្ឋល្អ។ លើសពីនេះទៅទៀតពេលកូនបានចាប់កំណើតឡើង លោកទាំងពីរបានពិបាកខិតខំពុះពារគ្រប់ឧបសគ្គទាំងឡាយ ទោះបីជាការងារទាំងនោះបានបង្កគ្រោះថ្នាក់ដល់ជីវិត ក៏លោកទាំងពីរមិនញញើតព្រោះដើម្បីចិញ្ចឹមជីវិតកូនឱ្យរស់សុខស្រួល និងផ្គត់ផ្គង់ឱ្យកូនបានសិក្សារៀបសូត្រ ក្នុងគោលដៅក្លាយជាមនុស្សម្នាក់ដ៏សំខាន់ដែលមិនអាចខ្វះបាន ក្នុងការចូលរួមអភិវឌ្ឍន៍សង្គមជាតិកម្ពុជា។ ជាពិសេស លោកអ្នកទាំងពីរមានគុណ គឺមិនអាចយកអ្វីមកប្រៀបធៀបបានឡើយ។

-**មិត្តភក្តិ** ដែលបានចំណាយពេលវេលា ដ៏មានតម្លៃ និងបានផ្តល់ជាមតិយោបល់កម្លាំងចិត្ត ដើម្បីជួយឱ្យយើងខ្ញុំមានថាមពល ក្នុងការបំពេញកិច្ចការងារនេះបានចប់ចុងចប់ដើម។

-**សាស្ត្រាចារ្យ** ដែលបានផ្តល់ពុទ្ធិ និងចែករំលែកបទពិសោធន៍ក្នុងការបង្ហាត់បង្រៀន ជួយលើកទឹកចិត្ត ត្រួសត្រាយផ្លូវ និងផ្តល់ជាដំបូន្មានល្អៗ គោលបំណងឱ្យកិច្ចការស្រាវជ្រាវនេះបានសម្រេច។ ជាពិសេស លោកគ្រូសាស្ត្រាចារ្យ **នី វិចិត្រ** ដែលបានជួយដឹកនាំ និងត្រួតពិនិត្យកំឡុងពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាមួយនេះបានយ៉ាងរលូន ក៏ប៉ុន្តែបើគ្មានវត្តមាន ប្រហែលជាយើងខ្ញុំមិនអាចសម្រេចនូវកិច្ចការមួយនេះបានដែរ គឺព្រោះតែលោកបានចំណាយពេលដ៏មានតម្លៃ ក្នុងការពិនិត្យ និងកែលម្អនូវសារណាមួយនេះឱ្យមានលក្ខណៈល្អប្រសើរ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យដោយលើកម្រាមដៃដប់ ប្រណម្យបួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងអស់ឱ្យបាននូវសិរីសួស្តីបវរមហាសិរីដល់លោកអ្នកដ៏មានគុណ និងសាស្ត្រាចារ្យទាំងអស់ទទួលបានជោគជ័យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន អាយុយឺនយូរ សុខភាពបរិបូរណ៍ និងសម្រេចរាល់ភារកិច្ចទាំងឡាយ។

សូមអរគុណ។

# អារម្ភកថា

ជាបឋម ខ្ញុំបាទ កក់ ជីវី និងខ្ញុំបាទ គីម មីនឃ្យូ និងស្វាគមន៍ចំពោះលោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិត និងបញ្ញវន្តទាំងអស់ ដែលបានចំណាយពេលដ៏មានតម្លៃក្នុងការអានសៀវភៅរបស់យើងខ្ញុំ ដែលបានរៀបរាប់ពីអំពី «**របបគតិយុត្តអនុវត្តចំពោះការគ្រប់គ្រងកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាក**» ។ សារណាមួយនេះ បានតាក់តែងឡើងនៅក្នុងឱកាសបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ហើយនេះក៏ជាឱកាសដ៏វិសេសវិសាលមួយដែលយើងខ្ញុំអាចវាស់ស្ទង់ចំណេះដឹងតាមរយៈការសិក្សាអស់រយៈពេល៤ឆ្នាំ និងការស្រាវជ្រាវបន្ថែម។

ការសម្រេចចិត្តជ្រើសរើសប្រធានបទនេះឡើង គឺក្នុងគោលបំណងសិក្សាបន្ថែមទៅលើរបៀបក្នុងការគ្រប់គ្រងកិច្ចសន្យាអាជ្ញាប័ណ្ណ ដោយឃើញពីសារៈប្រយោជន៍នៃវិស័យសេដ្ឋកិច្ច ក៏ដូចជាវិស័យពាណិជ្ជកម្មទាក់ទងនឹងវិវាទនិងដំណោះស្រាយផ្សេងៗដែលក្នុងនោះ មានវិបត្តិដែលទាក់ទងរវាងច្បាប់នឹង ការអនុវត្តជាក់ស្តែង។

ទោះបីជា យើងខ្ញុំបានពិនិត្យ និងកែសម្រួលជាច្រើនលើក ជាច្រើនសារហើយក្តី ក៏យើងខ្ញុំបានដឹងច្បាស់ថានៅមានកង្វះខាតចំណុចមួយចំនួន អត្ថន័យ ឬខ្លឹមសារណាមួយពិតជាជៀសមិនផុតនោះឡើយ។

អាធ្យាស្រ័យដូចដែលបានជម្រាបខាងលើ សូមលោក លោកស្រី សាស្ត្រាចារ្យ សិស្ស និស្សិត និងបញ្ញវន្តទាំងអស់ មេត្តាអធ្យាស្រ័យនូវរាល់កំហុសឆ្គងដែលបានកើតឡើងដោយអចេតនា ដោយក្តីអនុគ្រោះ។ សូមអរគុណ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................................................................ ១

## ជំពូកទី១
## យន្តការនៃការបង្កើតកិច្ចសន្យាអាដ្ឋាប័ណ្ណម៉ាក

**ផ្នែកទី១៖ លក្ខខណ្ឌផ្លូវច្បាប់នៃការបង្កើតកិច្ចសន្យានៃម៉ាក** ........................................ ៣

**កថាខណ្ឌទី១៖ គោលបំណងកិច្ចសន្យាអាដ្ឋាប័ណ្ណនៃម៉ាក** ........................................ ៣

១. លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាក ........................................ ៤

១.១. កិច្ចសន្យាទិញលក់ម៉ាក ........................................ ៤

១.២. លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាទិញលក់ ........................................ ៨

១.៣. លក្ខខណ្ឌផ្លូវច្បាប់ក្នុងការបង្កើតកិច្ចសន្យាអនុប្បទាន ........................................ ១០

១.៤. លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាអនុប្បទាន ........................................ ១១

**កថាខណ្ឌទី២៖ កិច្ចសន្យាជួលម៉ាក** ........................................ ១១

២. លក្ខខណ្ឌតតាំងនៃភតិសន្យា ........................................ ១១

២.១. លក្ខខណ្ឌតតាំងនៃសិទ្ធិជួលអចលនវត្ថុ ........................................ ១២

២.២. លក្ខខណ្ឌទម្រង់នៃភតិសន្យា ........................................ ១៦

២.៣. «ខ» ពិសេសក្នុងការបង្កើតកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក ........................................ ១៨

២.៤. លក្ខខណ្ឌទម្រង់នៃការបង្កើតកិច្ចសន្យាជួលម៉ាក ........................................ ១៨

**កថាខណ្ឌទី៣៖ បញ្ហាប្រឈម** ........................................ ១៩

១. ការកង្វះនូវលិខិតបទដ្ឋានគតិយុត្ត ........................................ ១៩

២. ការកង្វះនូវធនធាន ........................................ ១៩

**កថាខណ្ឌទី៤៖ ដំណោះស្រាយ** ........................................ ២០

## ជំពូកទី២
## លក្ខខណ្ឌនៃការចុះបញ្ជីអាដ្ឋាប័ណ្ណម៉ាក

**ផ្នែកទី១៖ លក្ខខណ្ឌនីតិវិធី និងឯកសារតម្រូវសម្រាប់ស្នើសុំការកត់ត្រា** ........................................ ២១

**កថាខណ្ឌទី១៖ លក្ខខណ្ឌតម្រូវទាក់ទងនឹងអ្នកស្នើសុំការកត់ត្រា** ........................................ ២១

១. លក្ខខណ្ឌតម្រូវទាក់ទងនឹងកិច្ចសន្យា ............ ២២

១.១. ពាក្យស្នើសុំកត់ត្រា ............ ២២

១.២. ការដាក់ពាក្យស្នើសុំកត់ត្រា ............ ២២

**កថាខណ្ឌទី២៖ នីតិវិធីនៃការត្រួតពិនិត្យពាក្យស្នើសុំកត់ត្រា** ............ ២៤

២. ការបដិសេធពាក្យស្នើសុំកត់ត្រា ............ ២៤

២.១. ការយល់ព្រមចំពោះការស្នើសុំកត់ត្រា និងការបោះពុម្ពផ្សាយ ............ ២៥

២.២. ការស្នើសុំកែតម្រូវពាក្យស្នើសុំកត់ត្រា ............ ២៥

២.៣. ការដកពាក្យស្នើសុំកត់ត្រា ............ ២៦

**កថាខណ្ឌទី៣៖ តម្លៃនៃការចុះបញ្ជីអាជ្ញាប័ណ្ណម៉ាក** ............ ២៦

**ផ្នែកទី២៖ អានុភាពនៃការកត់ត្រា** ............ ២៦

**កថាខណ្ឌទី១៖ សុពលភាពសិទ្ធិនិងកាតព្វកិច្ច** ............ ២៦

១. សុពលភាពនៃការកត់ត្រា ............ ២៦

១.២. ការបន្តសុពលភាពនៃការកត់ត្រា ............ ២៦

១.៣. ការបាត់បង់សុពលភាពជាស្វ័យប្រវត្តិនិងការលុបចោលការកត់ត្រា ............ ២៧

១.៤. មោឃភាពនៃការកត់ត្រា ............ ២៧

**កថាខណ្ឌទី២៖ ការផ្លាស់ប្តូរផ្សេងៗទាក់ទងនឹងការកត់ត្រា** ............ ២៨

២. ការកែតម្រូវកំហុសបច្ចេកទេស ............ ២៨

២.១. សិទ្ធិទទួលបានពីការកត់ត្រា ............ ២៩

២.២. កាតព្វកិច្ចកើតចេញពីការកត់ត្រា ............ ២៩


## ជំពូកទី៣

## យន្តការនៃការអនុវត្តកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាក


**ផ្នែកទី១៖ ការប្រៀបធៀបកិច្ចសន្យាទិញលក់ ម៉ាក និង កិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាក** ............ ៣១

**កថាខណ្ឌទី១៖ ការទូទាត់សរុប** ............ ៣១

**កថាខណ្ឌទី២៖ ថ្លៃឈ្នួល** ............ ៣១

**ផ្នែកទី២៖ ការប្រៀបធៀបកិច្ចសន្យាជួល ម៉ាក និង កិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាក** ............ ៣២

**ផ្នែកទី៣៖ ករណីសិក្សា** ............ ៣៣

**កថាខណ្ឌទី១៖ អង្គហេតុ** ............ ៣៣

**កថាខណ្ឌទី២៖ ការទាមទារនិងការវិនិច្ឆ័យ** ........ ៣៣
១. ការទាមទាររបស់ភាគី........ ៣៣
២. ការវិនិច្ឆ័យ........ ៣៤
**កថាខណ្ឌទី៣៖ សន្និដ្ឋាន** ........ ៣៥
**សេចក្តីសន្និដ្ឋាន** ........ ៣៦
**អនុសាសន៍** ........ ៣៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

ប្រទេសកម្ពុជាបានចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្នុងឆ្នាំ ២០០៤ ដោយក្នុងនោះដែរគឺមានការចុះសន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងផ្សេងៗទៀត ដែលទាក់ទងទៅនឹងវិស័យពាណិជ្ជកម្ម ជាពិសេសគឺទាក់ទងទៅនឹង ផ្នែកកម្មសិទ្ធិបញ្ញាដូចជា ប្រកាសនីយបត្រតក្កកម្ម ម៉ាកសម្គាល់ទីតាំងភូមសាស្ត្រនៃទំនេញ គំនូរឧស្សាហកម្ម និងការសម្ងាត់របស់ម៉ាក។ល។ ដែលជាហេតុធ្វើឱ្យប្រទេសកម្ពុជាបានបង្កើតនូវច្បាប់ និងបទប្បញ្ញត្តដែលទាក់ទងតៅនឹងវិស័យ និងផ្នែកទាំងអស់នៃកម្មសិទ្ធិបញ្ញា។

ដោយសារតែប្រទេសកម្ពុជា បានប្រកាន់ភ្ជាប់នូវគោលនយោបាយប្រព័ន្ធទីផ្សារសេរី ដូចនេះគឺប្រាកដនឹងមានការប្រកួតប្រជែងយ៉ាងមុតមាំដែលធ្វើឱ្យពាណិជ្ជករនានាជៀសមិនផុតពីនោះឡើយ។ ជាពិសេសគឺម៉ាកដែលបានដើរតួយ៉ាងសកម្មក្នុងទីផ្សារសេដ្ឋកិច្ចកម្ពុជាយ៉ាងក្តៅគគុក ដែលជាហេតុធ្វើឱ្យមានការលក់ និងជួលក្នុងវិស័យម៉ាក ដោយឡែកដោយមានរឿងរ៉ាវនិងការប្តឹងផ្តល់គ្នាជាច្រើនទាក់ទងទៅនឹងម៉ាកដូដនេះហើយក៏ឈានទៅរកការបង្កើតកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាកដើម្បីជួយឱ្យដំនើរការអាជីវកម្មប្រព្រឹត្តទៅដោយរលូន និងសុវត្ថិភាព។ ថ្វីត្បិតតែមានកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកក៏ពិតមែន ប៉ុន្តែនៅមានបញ្ហាជាច្រើនទៀតដែលកើតឡើងជាបន្តបន្ទាប់ ដូចជាមានជនខិលខូចមួយចំនួនបានលួចយកឈ្មោះម៉ាករបស់ម្ចាស់ដើម ទៅប្រកបអាជីវកម្មដោយគ្មានការអនុញ្ញាតនិងមិនមានការចុះបញ្ជីត្រឹមត្រូវ ហើយច្បាប់កម្ពុជាក៏ពុំទាន់ស៊ីជម្រៅទាក់ទងនឹងកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក ដូចនេះហើយទើបយើងខ្ញុំបាទក៏បានជ្រើសរើសប្រធានបទ៖ **របបគតិយុត្តអនុវត្តគ្រប់គ្រងចំពោះកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក**៖ មកបកស្រាយឱ្យបានច្បាស់លាស់ ដោយសារនីតិកម្មសិទ្ធបញ្ញាកម្ពុជាគឺភាគច្រើនគ្របដណ្តប់ទៅលើវិស័យកម្មសិទ្ធិបញ្ញាច្រើន តែយើងបានជ្រើសយកចំនុចកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកនេះមកនិយាយមកពន្យល់ និងបកស្រាយតែប៉ុណ្ណោះ គឺយើងពុំបានបកស្រាយទៅលើលក្ខខណ្ឌវិវាទទៅលើកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកនេះឡើយ។ ដើម្បីពន្យល់នឹងបកស្រាយឱ្យបានច្បាស់ថា តើរបបគតិយុត្តមួយណាទើបសាកសមយកមកអនុវត្តនិងគ្រប់គ្រងទៅលើកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក និងដើម្បីធ្វើឱ្យមានការរីកចម្រើនលើវិស័យកម្មសិទ្ធិបញ្ញា ជាពិសេសគឺវិស័យម៉ាកនៅកម្ពុជា។ តើអ្វីទៅជារបប? តាមវចនានុក្រមសម្តេចជួន ណាត របបមានន័យថាជារបៀបរៀបរយ, សណ្តាប់ធ្នាប់។ តើអ្វីទៅជាគតិយុត្ត? តាមសន្ទានុក្រមច្បាប់ខ្មែរអង់គ្លេស,បារាំង «ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី»ពាក្យថាគតិយុត្តមានន័យថា តាមគន្លងច្បាប់ ដែលទាក់ទងនិងច្បាប់ ដែលត្រឹមត្រូវតាមច្បាប់។ តើអ្វីទៅជាកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក? នៅក្នុងប្រព័ន្ធច្បាប់ Civil Law ដែលយើងអាចហៅថាច្បាប់រដ្ឋប្បវេណីគឺនៅក្នុងក្រមមិនបានចែងអំពីនិយមន័យរបស់**កិច្ចសន្យាអាជ្ញាប័ណ្ណ**នោះទេគឺមានតែពាក្យថា**កិច្ចសន្យា** កិច្ចសន្យាគឺជាកិរិយា ដែលបុគ្គលពីរនាក់ ឬ ច្រើននាក់

មានឆន្ទៈ ត្រូវគ្នា ព្រមបង្កើត កែប្រែ ឬរំលត់ការព្វកិច្ច[1]។ ចំណែកឯពាក្យថាកិច្ចសន្យាអាជ្ញប័ណ្ណគឺភាគច្រើនគឺគេយកការអនុវត្តជាក់ស្តែងនៅក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកមកប្រើប្រាស់និងដាក់និយមន័យឱ្យពាក្យ ម៉្យាងវិញទៀតនៅក្នុងប្រកាសរបស់ក្រសួងពាណិជ្ជកម្មបានឱ្យនិយមន័យទៅលើពាក្យ**កិច្ចសន្យាអាជ្ញាប័ណ្ណ** ថាគឺសំដៅដល់កិច្ចសន្យាមួយដែលម្ចាស់ម៉ាកដែលបានចុះបញ្ជី ឬបានដាក់ពាក្យស្នើសុំចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាផ្តល់អាជ្ញាប័ណ្ណម៉ាកនោះឱ្យទៅបុគ្គលណាមួយ។ រាល់កិច្ចសន្យាទាំងឡាយណា ដែលមានចែងទាក់ទងនឹងការផ្តល់អាជ្ញាប័ណ្ណប្រប្រាស់ម៉ាកនៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺត្រូវរាប់បញ្ចូលជាកិច្ចសន្យាអាជ្ញាប័ណ្ណលើម៉ាកផងដែរ។

ជាមួយគ្នានេះដែរក៏មានចំណោទបញ្ហាមួយបានលើកឡើងថា៖

-តើរបបគតិយុត្តមួយណាដែលសាកសមយកមកអនុវត្តទៅលើកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក?

-ប្រសិនបើមិនបានចុះបញ្ជី តើកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាកអាចអនុវត្តបានដែរឬទេ?

-តើមានវិធានការណ៍ ឬលក្ខខណ្ឌអ្វីសម្រាប់តតាំងជាមួយតតិយជន នៅពេលដែលតតិយនោះលួចយកម៉ាករបស់ម្ចាស់ដើទៅប្រើប្រាស់ ដោយមិនមានការយល់ព្រមឬចុះបញ្ជីពីម្ចាស់ដើម?

-តើមានយន្តការអ្វីខ្លះ សម្រាប់យកមកអនុវត្តលើកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក?

មុននឹងបកស្រាយប្រធានបទខាងលើនេះយើងខ្ញុំបាទបានធ្វើការសិក្សាជាពីរជំពូកគឺ យន្តការក្នុងការបង្កើតកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក(ជំពូកទី១) លក្ខខណ្ឌក្នុងការចុះបញ្ជីអាជ្ញាប័ណ្ណម៉ាក(ជំពូកទី២) និងយន្តការនៃការអនុវត្តកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក(ជំពូកទី៣)។

[1] *សន្ទានុក្រមរដ្ឋប្បវេណី* ចំនុចទី១៥, ទំព័រទី២ ។

# ជំពូកទី១

# យន្តការនៃការបង្កើតកិច្ចសន្យាអាជ្ញាប័ណ្ណ

## ផ្នែកទី១៖ លក្ខខណ្ឌផ្លូវច្បាប់នៃការបង្កើតកិច្ចសន្យានៃម៉ាក

នៅក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកនីមួយៗ គឺត្រូវឆ្លងកាត់ផ្លូវច្បាប់ដើម្បីធ្វើឱ្យកិច្ចសន្យានោះកាន់តែមានប្រសិទ្ធិភាព និងសុពលភាពជាពិសេសគឺត្រូវអនុវត្តតាមបទប្បញ្ញត្តិ និងបទដ្ឋាននានាដើម្បីផ្តល់ជាភាពងាយស្រួលក្នុងការដោះស្រាយបញ្ហានានា ព្រោះមានតែការអនុវត្តតាមនីតិវិធីផ្លូវច្បាប់ទេដែលអាចធ្វើឱ្យកិច្ចសន្យាអាជ្ញាប័ណ្ណក្លាយជាកិច្ចសន្យាដែលត្រឹមត្រូវនិងទទួលស្គាល់ដោយច្បាប់។ ហើយការបង្កើតកិច្ចសន្យាអាជ្ញាប័ណ្ណគឺមិនខុសពីការបង្កើតកិច្ចសន្យាទូទៅឡើយពោល គឺត្រូវបំពេញលក្ខខណ្ឌទាំងឡាយនៃការបង្កើតកិច្ចសន្យា។

### កថាខណ្ឌទី១៖ គោលបំណងកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាក

ដើម្បីស្វែងយល់ពីគោលបំណងនៃកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកគឺយើងត្រូវដឹងអំពី គោលបំណងនៃម៉ាក និងគោលបំណងនៃកិច្ចសន្យាអាជ្ញាប័ណ្ណជាមុនសិន៖

**ក. គោលបំណងនៃម៉ាក៖** តាមរយៈការប្រើប្រាស់ម៉ាក អតិថិជនអាចធ្វើការបែងចែកប្រភព ឬអត្តសញ្ញាណនៃទំនិញ ឬសេវារបស់សហគ្រាសមួយទៅសហគ្រាសមួយទៀតដែលជាដៃគូប្រកួតប្រជែងរបស់ខ្លួន។ វាជាកាផ្តល់ជម្រើសមួយដល់អតិថិជន និងជាឱកាសក្នុងការប្រកួតប្រជែងរបស់សហគ្រាស។ ក្នុងករណីនេះ ម្ចាស់ម៉ាកមានសិទ្ធិហាមឃាត់តតិយជន ឬដៃគូប្រកួតប្រជែងមិនឱ្យប្រើប្រាស់ម៉ារបស់ខ្លួនម៉ាកដែលដូច ឬស្រដៀងនិងម៉ាករបស់ខ្លួនដែលសិទ្ធិទាំងនេះត្រូវមានតាមរយៈ ការចុះបញ្ជីម៉ាកស្របតាមច្បាប់រដ្ឋដែលសគ្រាសនោះកំពុងធ្វើ អាជីវកម្ម។ ការចុះបញ្ជីតាមច្បាប់ជាតិនីមួយៗផ្តល់នូវសិទ្ធិផ្តាច់មុខដល់ម្ចាស់ម៉ាកក្នុងការប្រើប្រាស់ក្នុងដែនដីនៃរដ្ឋ ដែលនោះត្រូវបានចុះបញ្ជី[2]។

**ខ. គោលបំណងនៃកិច្ចសន្យាអាជ្ញាប័ណ្ណ៖** គឺដើម្បីការពារពីការអនុវត្តសិទ្ធិហួសកម្រិតដោយអ្នកទទួលអាជ្ញាប័ណ្ណ និងដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់អ្នកផ្តល់អាជ្ញាប័ណ្ណ។

ដូចនេះគោលបំណងនៃកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកគឺដើម្បីការពារសិទ្ធិរបស់អ្នក ដែលផ្តល់អាជ្ញាប័ណ្ណម៉ាកពីការប្រើប្រាស់សិទ្ធិហួសកម្រិតរបស់អ្នកដែលទទួលអាជ្ញាប័ណ្ណម៉ាក និងជៀសវាងការប្រកួតប្រជែងដែលមិនប្រើប្រាស់ម៉ាករបស់ខ្លួនដែលម៉ាកនោះគឺមានតាមរយៈតាមការចុះបញ្ជីស្របតាមច្បាប់រដ្ឋ[3]។ ដោយឡែកនៅក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកគឺមិនមានការកំណត់របបគតិយុត្តច្បាស់លាស់ហើយ កិច្ចសន្យាអាជ្ញាប័ណ្ណនេះគឺគួរតែ

---

[2] នី វិចិត្រ, "នីតិកម្មសិទ្ធិបញ្ញាកម្ពុជា" (បោះពុម្ពលើកទី១, ២០១៣). ១៨៣។

[3] ដដែល, ទំព័រ១៣២។

ចាត់វិធានការស្របច្បាប់តាមរយៈការតាក់តែងបទប្បញ្ញត្តជាក់លាក់ និងច្បាស់លាស់ស្របតាមគោការណ៍ច្បាប់ដែលពាក់ព័ន្ធនឹងកិច្ចសន្យាដើម្បីការពារផលប្រយោជន៍ខ្លួនឯង។ ដូច្នេះក្នុងកិច្ចសន្យាមួយដើម្បីឱ្យកិច្ចសន្យានោះស្របច្បាប់និងមានសុពលភាពគឺត្រូវតែគោរពតាមគោលការណ៍ដូចជា៖

**១. ឆន្ទៈរបស់គូភាគី៖** កិច្ចសន្យា ឬការសន្យាណាក៏ដោយ ក៏ត្រូវតែធ្វើឡើងតាមឆន្ទៈរបស់គូភាគី ពោលគឺត្រូវតែធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំពីសំណាក់ភាគីនៃកិច្ចសន្យាឬជនទីបីដែលពាក់ព័ន្ធនឹងផលប្រយោជន៍ក្នុងកិច្ចសន្យានោះទេ។ ម្យ៉ាងទៀតច្បាប់ក៏មិនអាចយកជាការបានដែរនៅពេលដែលគូភាគីណាម្នាក់ចុះកិច្ចសន្យាដោយកាលៈទេសៈ ឬ ស្ថានភាពសេដ្ឋកិច្ចណាមួយមកបង្ខំ[4]។

**២. កម្មវត្ថុនៃកិច្ចសន្យា៖** ដើម្បីធ្វើកិច្ចសន្យាមួយបាន លុះត្រាតែកិច្ចសន្យានោះធ្វើឡើងដោយមានកម្មវត្ថុច្បាស់លាស់ និងជាកម្មវត្ថុដែលស្ថិតនៅក្នុងពាណិជ្ជកម្ម ពោលគឺកម្មវត្ថុដែលច្បាប់អនុញ្ញាតឱ្យមានការរកស៊ីដូរបានក្នុងទីផ្សារ។ ភាគីមិនអាចចុះកិច្ចសន្យាទិញគ្រឿងញៀនកិច្ចសន្យាភ្នាល់បាល់ ប្រដាល់ ឬ ជល់មាន់និងលក់គ្រឿងសេរីរាង្គមនុស្សជាដើម គឺជាកិច្ចសន្យាដែលមានកម្មវត្ថុក្រៅកិច្ចសន្យាពោលគឺត្រូវបានហាមឃាត់ដោយច្បាប់[5]។

**៣. សមត្ថភាពរបស់គូភាគី៖** បុគ្គលដែលជាអ្នកធ្វើកិច្ចសន្យាគឺត្រូវជាបុគ្គលដែលមានសមត្ថភាព ដែលទទួលខុសត្រូវដោយច្បាប់ ពោលគឺជាភាគីឬបុគ្គលដែលមានស្មារតីត្រឹមត្រូវជាមនុស្សដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ និងជាបុគ្គលដែលត្រូវបានអនុញ្ញាតដោយច្បាប់ថាពិតជាមានសមត្ថភាពក្នុងការចុះកិច្ចសន្យាបាន។ ក្នុងករណីនេះមនុស្សដែលមានវិប្បល្លាស់ស្មារតី និងមនុស្សចាស់ជរាវង្វេងម្តងម្កាលគឺមិនអាចចាត់ទុកថាជាមនុស្សដែលមានសមត្ថភាពដែលអាចចុះកិច្ចសន្យាបានទេ[6]។

ដោយកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាកគឺមិនមានច្បាប់ ឬ របបគតិយុត្តឱ្យច្បាស់លាស់នោះទេគឺត្រូវអនុវត្តដោយវិធានរួម ដូចនេះបើយើងនិយាយអំពីកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកគឺ យើងអាចសំដៅដល់អំពីកិច្ចការទិញលក់ ឬការជួលទៅលើម៉ាកដែលវិធានទាំងអស់នេះគឺកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកបានយកជាគំរូ និងការអនុវត្តតាមលក្ខខណ្ឌទាំងឡាយក្នុងការបង្កើតកិច្ចសន្យានៅក្នុងក្រមរដ្ឋប្បវេណី។

## ១. លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាក

### ១.១. កិច្ចសន្យាទិញលក់ម៉ាក

ការធ្វើកិច្ចសន្យាម៉ាកនៅកម្ពុជា គឺភាគច្រើនគេអនុវត្តតាមកិច្ចសន្យាទូទៅដូចនៅក្នុងក្រមរដ្ឋប្បវេណីដែរ

---

4 លី កុសល “លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា” (ឯកសារថតចម្លង, ២០១៨)។

5 ដូច4។

6 ដូច4។

ហើយការធ្វើកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក នៅកម្ពុជាពាក់ព័ន្ធនឹងច្បាប់កម្មសិទ្ធិបញ្ញាក្នុងនីតិកម្មសិទ្ធិបញ្ញាកម្ពុជា គឺយើងពុំឃើញមានបទប្បញ្ញត្តពិសេសដែលកំណត់អំពីរបបគតិយុត្តគ្រប់គ្រងលើកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក នៅឡើយទេ។ ដូច្នេះនៅក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណនៅក្នុងច្បាប់កម្ពុជាគឺ ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃនីតិរួមគឺលក្ខខណ្ឌគតិយុត្តទាំងឡាយ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាស្តីពីការបង្កើតកិច្ចសន្យា។ ដូចនេះយើងអាចអនុវត្តកិច្ចសន្យាទិញលក់អាជ្ញាប័ណ្ណម៉ាកតាមលក្ខខណ្ឌនៃកិច្ចសន្យាទិញលក់ក្នុងក្រមរដ្ឋប្បវេណីដែរ ដែលក្នុងនោះកិច្ចសន្យាទិញលក់អាចបានបង្កើតឡើងដោយមានការព្រមព្រៀងរវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់។ ប៉ុន្តែភាគីអាចកំណត់ការធ្វើលិខិតយថាភូត ឬលិខិតឯកជន ជាលក្ខខណ្ឌសម្រាប់ការបង្កើតកិច្ចសន្យាបាន។

កិច្ចសន្យាទិញលក់ ត្រូវតែកើតឡើងពីការព្រមព្រៀងគ្នាដោយសេរី និងពិតប្រាកដមានន័យថាជាការព្រមព្រៀងគ្នាដោយគ្មានវិការៈ។ ការព្រមព្រៀងដោយសេរីមានន័យថា ការព្រមព្រៀងកើតឡើងចេញពីឆន្ទៈដោយផ្ទាល់របស់បុគ្គលនោះដោយគ្មានការបង្ខិតបង្ខំ ទាំងទៅលើរូបរាងកាយ និងទៅលើផ្លូវចិត្ត។ ក្នុងន័យនេះភាគីអ្នកលក់ និងអ្នកទិញត្រូវតែមានការព្រមព្រៀងគ្នាដោយគ្មានការបង្ខិតបង្ខំ ក្នុងការលក់ ឬ ទិញ មានន័យថា អ្នកទិញមានឆន្ទៈក្នុងការទិញ ចំណែកឯអ្នកលក់មានឆន្ទៈក្នុងការលក់ដែរ[7]។

ការព្រមព្រៀងដោយគ្មានវិការៈសំដៅទៅលើការព្រមព្រៀង ដែលកើតចេញពីការបន្លំបោកប្រាស់ការភ័ន្តច្រឡំ ការប្រើអំពើហិង្សា និងការឆ្លៀតឱកាសចំណេញហួសហេតុ។

ដូច្នេះការព្រមព្រៀងដោយគ្មានវិការៈ គឺជាការព្រមព្រៀង ដែលមិនមែនកើតចេញពី ការបន្លំបោសប្រាស់ការភ័ន្តច្រឡំការប្រើអំពើហិង្សា និងការឆ្លៀតឱកាសចំណេញហួសហេតុមានន័យថារាល់ការព្រមព្រៀងរវាងអ្នកលក់ និងអ្នកទិញត្រូវតែគ្មានវិការៈ។

កាលណាការព្រមព្រៀងនោះមានវិការៈ ភាគីទាំងពីរអាចសុំលុបកិច្ចសន្យានេះចោលបាន ដោយបង្ហាញភស្តុតាងថាការព្រមព្រៀងនៃកិច្ចសន្យានេះមានវិការៈ[8]។

- **សមត្ថភាពរបស់គូភាគី**

**ក. ចំពោះអ្នកលក់**

សមត្ថភាព ក្នុងន័យនេះមានន័យថា អ្នកលក់ ត្រូវតែជាមនុស្សដែលមានសមត្ថភាព ពោលគឺត្រូវតែជានីតិជន។ នីតិជន គឺជាជនដែលមានអាយុគ្រប់តាមការកំណត់របស់ច្បាប់[9]។

---

[7] យស បានចំរុង និងខាំ សុមករា, “នីតិកិច្ចសន្យាពិសេស” (ឯកសារថតចម្លង, ២០១៣). ៩។

[8] ដដែល, ទំព័រ៩។

[9] ដដែល, ទំព័រ៩។

តាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មាត្រា ១៧ បានឱ្យនិយមន័យ អនីតិជនថាជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ ។ តាមមាត្រានេះបានឱ្យដឹងថា ដើម្បីមានសមត្ថភាពទទួលបាននូវសិទ្ធិពេញលេញ ជននោះត្រូវតែមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅទើបអាចធ្វើសកម្មភាពបានពេញលេញ។ បើយើពិនិត្យមើលក្រមរដ្ឋប្បវេណីសង្គមចាស់ ឆ្នាំ១៩២០ និងក្រមរដ្ឋប្បវេណីអាឡឺម៉ង់ និងក្រមរដ្ឋប្បវេណីជប៉ុន ២០ ឆ្នាំជានីតិជន។

តាមរយៈសមត្ថភាពនេះ មិនមែនមានន័យថា ឱ្យតែជននោះមានអាយុគ្រប់ ១៨ ឆ្នាំហើយ គឺសុទ្ធតែមានសមត្ថភាពពេញលេញនោះទេ។ ដើម្បីឱ្យជននោះមានសមត្ថភាពពេញលេញ ក្នុងការធ្វើសកម្មភាពបានត្រឹមត្រូវតាមច្បាប់នោះគឺ ទាល់តែបុគ្គលនោះ មិនត្រូវបានកម្រិតសកម្មភាពតាមច្បាប់ក្នុងការធ្វើសកម្មភាពរបស់ខ្លួនឡើយ។

តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៦ មានធ្វើការកម្រិតជនដែលមិនអាចធ្វើសកម្មភាពបានមាន អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមបបហិតូបត្ថម្ភ។ បញ្ជាក់អំពីអនីតិជនមានអត្តាធិនភាព គឺមានសមត្ថភាពពេញលេញក្នុងការចុះកិច្ចសន្យាដូចនីតិជនដែរ[10]។

លើសពីនេះទៅទៀតអ្នកលក់គឺត្រូវតែជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើទ្រព្យ ឬ វត្ថុដែលខ្លួនលក់ បើមិនដូច្នេះទេការលក់នេះត្រូវទុកជាមោឃៈ។

**ខ. ចំពោះអ្នកទិញ**

មិនមែនមានន័យថាឱ្យតែ រូបវន្តបុគ្គល ឬ នីតិបុគ្គល សុទ្ធតែអាចក្លាយជាអ្នកទិញបានទាំងអស់នោះទេ មានបុគ្គលមួយចំនួន ដែលច្បាប់បានធ្វើការហាមឃាត់ មិនឱ្យក្លាយជាអ្នកទិញហើយការដែលច្បាប់ធ្វើការហាមឃាត់នេះគឺដើម្បីផលប្រយោជន៍របស់ភាគីអ្នកលក់។ សមត្ថភាពរបស់អ្នកទិញមានលក្ខណៈដូចគ្នា និងសមត្ថភាពរបស់អ្នកលក់ដែរ តែអ្វីដែលមានលក្ខណៈប្លែកនោះគឺច្បាប់បានធ្វើការហាមឃាត់នូវបុគ្គលមួយចំនួនតាមផ្លូវច្បាប់ មិនឱ្យធ្វើសកម្មភាពក្នុងការទិញដើម្បីជៀសវៀងបាត់បង់តម្លៃក្នុងការទិញ។ បុគ្គលដែលច្បាប់បានធ្វើការហាមឃាត់មិនអាចក្លាយជាអ្នកទិញតាមផ្លូវច្បាប់មានដូចជាៈ

ក. អ្នកគ្រប់គ្រងទ្រព្យសម្បត្តិតាមផ្លូវច្បាប់ តាមផ្លូវតុលាការ ឬតាមកិច្ចសន្យា មិនអាចក្លាយជាអ្នកទិញ ឬជាអ្នកទិញដោយការលក់ដោយបង្ខំនូវទ្រព្យសម្បត្តិដែលខ្លួនទទួលភារកិច្ចលក់ដោយផ្ទាល់ ឬ តាមរយៈអន្តរការីបានឡើយ។ មន្ត្រីដែលទទួលបន្ទុកចាត់ការការលក់ដោយបង្ខំឬទទួលបន្ទុកគ្រប់គ្រងការលក់ដោយបង្ខំ។

ខ. ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី ឬ មន្ត្រីតុលាការផ្សេងទៀត មិនអាចក្លាយជាអ្នកទិញ ឬ

[10] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា២២ (ពីពេលនេះតទៅហៅថា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

ជាអ្នកទិញដោយការលក់ដោយបង្ខំដោយផ្ទាល់ខ្លួនឬ តាមរយៈអន្តរការីនូវវត្ថុ ឬ សិទ្ធិដែលជាកម្មវត្ថុនៃវិវាទដែលកំពុងចាត់ការនៅតុលាការដែលខ្លួនបំពេញភារកិច្ចបានទេ។

គ. មេធាវី ឬ សាការី ក្លាយជាអ្នកទិញ ឬ ជាអ្នកទិញដោយសារការលក់ដោយបង្ខំនូវវត្ថុ ឬ សិទ្ធិដែលទាក់ទងនឹងរឿងក្តីដែលខ្លួនបានទទួលបន្ទុក[11]។

❖ **កម្មវត្ថុនៃកិច្ចសន្យាទិញលក់**

កម្មវត្ថុនៃកិច្ចសន្យាទិញលក់ មានពីរប្រភេទគឺអាចវត្ថុ និងអាចជាសិទ្ធិ។ នៅក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណកម្មវត្ថុនៃកិច្ចសន្យានេះគឺសិទ្ធិ។

**សិទ្ធិ៖** សិទ្ធិគឺសំដៅសិទ្ធិគ្រប់គ្រងវត្ថុលក់ទិញ ដែលត្រូវបានផ្ទេរទៅឱ្យភាគីម្ខាងទៀត ហៅថាអ្នកទិញ (មាត្រា ៥១៥) ។ និងលើវត្ថុដែលមិនអាចបំបែកបាន ឬ មិនអាចផ្លាស់ប្តូរលក្ខណៈដើមនៃសមាសធាតុ (មាត្រា ១២១ និង មាត្រា ១២៥)។

ហើយកិច្ចសន្យាទិញលក់គឺជាកិច្ចសន្យាដែលភាគីម្ខាង(អ្នកលក់) មានករណីកិច្ចត្រូវផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិផ្សេងទៀតលើទ្រព្យសម្បត្តិឱ្យទៅភាគីម្ខាងទៀត(អ្នកទិញ) ហើយអ្នកទិញមានករណីកិច្ចត្រូវចេញថ្លៃជាប្រាក់ឱ្យទៅអ្នកលក់។

❖ **តម្លៃនៃកិច្ចសន្យាទិញលក់**

កិច្ចសន្យាទិញលក់ជាកិច្ចសន្យាអញ្ញមញ្ញ (ជាប្រភេទកិច្ចសន្យាមួយដែលមានការបំពេញកាតព្វកិច្ចទៅវិញទៅមករបស់ភាគី) ដែលតម្រូវឱ្យភាគីទាំងពីរ ត្រូវមានកាតព្វកិច្ចទៅវិញទៅមក មានន័យថាភាគីម្ខាងទៀតមានកាតព្វកិច្ចប្រគល់វត្ថុ ហើយភាគីម្ខាងទៀត មានកាតព្វកិច្ចប្រគល់លុយជាថ្នូរនឹងវត្ថុដែលបានប្រគល់។ គេអាចនិយាយម៉្យាងទៀត កិច្ចសន្យាលក់ទិញជាកិច្ចសន្យាមូលា ព្រោះកិច្ចសន្យានេះត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកប្រយោជន៍ និង ថ្នូរទៅវិញទៅមក[12]។

តម្លៃ៖ គឺពិតជាមានសារៈសំខាន់ណាស់ចំពោះកិច្ចសន្យាលក់ទិញ ពីព្រោះកិច្ចសន្យាលក់ទិញ ត្រូវតែមានតម្លៃជាថ្នូរ ដែលខុសពីកិច្ចសន្យាដូរដែលគ្មានតម្លៃជាថ្នូរឡើយ ដូច្នេះការកំណត់តម្លៃវាជាកត្តាមួយសំខាន់ណាស់ចំពោះភាគីអ្នកលក់ តែអ្វីដែលសំខាន់នោះគឺ ជារបៀប និងបច្ចេកទេសនៃការកំណត់តម្លៃ ថាតើយើងត្រូវធ្វើត្រូវតាមរបៀបណា ដើម្បីឱ្យមានភាពសុក្រឹត្យនោះ[13]។

---

[11] ក្រមរដ្ឋប្បវេណី២០០៧, មាត្រា៥២៥។

[12] ដូច7, ទំព័រ១៣។

[13] ដដែល, ទំព័រ១៤។

ការកំណត់នូវតម្លៃអាចយកតាមទីផ្សារឬតាមការព្រមព្រៀងរបស់ភាគីទាំងសងខាង។ ក្នុងន័យនេះ ទោះបីជាតម្លៃនោះមិនទាន់ត្រូវបានបាត់បង់ក៏ដោយក៏កិច្ចសន្យាអាចកើតមានបានដែរ។ មានកិច្ចសន្យាមួយចំនួនការបង់ថ្លៃត្រូវបាបធ្វើតាមក្រោយ ក្រោយពីមានការដឹកទំនិញដល់ផ្ទះ ឬ ក្រោយពីមានការប្រគល់ទំនិញជាដើម។ កាលណាកិច្ចសន្យាមួយគ្មានតម្លៃជាថ្លូវទេនោះមិនមែនជាកិច្ចសន្យាលក់នោះទេ តែវាជាកិច្ចសន្យាដូរទៅវិញ ហើយភាគីនៃកិច្ចសន្យាត្រូវកំណត់ចំនួនប្រាក់នៃថ្លៃលក់ទិញ ឬ វិធីកំណត់ចំនួនប្រាក់នោះនៅក្នុងកិច្ចសន្យាលក់ទិញនោះ។ ចំនួនប្រាក់នៃថ្លៃលក់ទិញអាចច្រើនបានកំណត់ដោយយោងទៅតាមតម្លៃនៃទំនិញណាមួយនៅទីផ្សារក្នុងពេលបច្ចុប្បន្ន ឬ អនាគត ឬ ដោយផ្អែកលើការវាយតម្លៃដែលធ្វើដោយតតិយជនដែលត្រូវបានជ្រើសរើសតាមរបៀបកំណត់ដោយគូភាគី។

ក្នុងករណីដែលការវាយតម្លៃរបស់តតិយជនត្រូវបានធ្វើឡើងដោយភ័ន្តច្រឡំ ឬករណីដែលការវាយតម្លៃនោះច្បាស់ជាផ្ទុយនឹងសមភាពភាគីនៃកិច្ចសន្យាដែលទទួលការខូចខាតផលប្រយោជន៍របស់ខ្លួនដោយសារការវាយតម្លៃនោះអាចតវ៉ាចំពោះការវាយតម្លៃនោះបាន។ ក្នុងករណីដែលតតិយជនវាយតម្លៃថ្លៃលក់ទិញត្រូវបានកំណត់ដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដ លើកលែងតែករណីដែលគូភាគីប្រគល់សិទ្ធិទៅ តតិយជនដោយជាក់លាក់។

### **១.២. លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាទិញលក់**

#### **ក. កិច្ចសន្យាទិញលក់ ឬ លិខិតឯកជន**

កិច្ចសន្យាឯកជន គឺជាកិច្ចសន្យាដែលធ្វើឡើងដោយគូភាគី តាមការព្រមព្រៀងណាមួយដើម្បីបង្កើតឱ្យមានលក្ខណៈតតិយុត្តតាមផ្លូវច្បាប់[14]។ កិច្ចសន្យាឯកជនគឺជាកិច្ចសន្យាដែលធ្វើឡើងតែគ្នាឯងឥតមានមន្ត្រីរាជការសាធារណៈណាមួយជួយដឹងលឺ ឬ ឃើញផងទេមានតែហត្ថលេខានៃគូភាគីតែប៉ុណ្ណោះ[15]។ កិច្ចសន្យាឯកជនអាចធ្វើឡើងដោយផ្ទាល់មាត់ និងលាយលក្ខណ៍អក្សរ។ ហើយច្បាប់អាចកំណត់ទម្រង់មួយជាក់លាក់ក្នុងការធ្វើកិច្ចសន្យា។ តាមក្រមរដ្ឋប្បវេណី មាត្រា៥១៧បានចែងថា៖ កិច្ចសន្យាទិញលក់អាចត្រូវបានបង្កើតឡើងដោយមានការព្រមព្រៀងគ្នារវាងភាគីទាំងសងខាងតែប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់។ ប៉ុន្តែភាគីអាចកំណត់ការធ្វើលិខិតយថាភូត ឬលិខិតឯកជនជាលក្ខខណ្ឌសម្រាប់ការបង្កើតកិច្ចសន្យាបាន។ តាមមាត្រានេះ មានន័យថា កិច្ចសន្យាទិញលក់អាចធ្វើឡើងដោយផ្ទាល់មាត់បាន តែត្រូវធ្វើ

[14] ដដែល, ទំព័រ១៤។

[15] ដដែល, ទំព័រ១៥។

ដោយលិខិតឯកជនបាន លើកលែងតែកិច្ចសន្យាមួយចំនួនដែលច្បាប់បានកំណត់នៅទម្រង់មួយជាក់លាក់ ដូចជាកិច្ចសន្យាលក់អចលនវត្ថុជាដើមដែលត្រូវធ្វើឡើងតាមទម្រង់លិខិតយថាភូត[16]។

### ខ. លិខិតយថាភូត

លិខិតយថាភូត គឺជាលិខិតដែលធ្វើឡើងដោយសាការី ឬ លិខិតឯកជន ដែលសាការីចុះនិទ្ទេសថាលិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់[17]។ ការធ្វើកិច្ចសន្យាតាមលិខិតយថាភូតនោះគឺដាច់ខាតត្រូវតែមាន មន្ត្រីដែលសមានសមត្ថកិច្ចចូលរួមក្នុងការធ្វើ ដូចជាតាមច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៦៥ បានចែងថា«ការផ្ទេរកម្មសិទ្ធិមុនអាចជំទាស់ពីអាជ្ញាធរមានសមត្ថកិច្ចហើយត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី»។ កិច្ចសន្យាលក់ឯកជន មិនអាចចាត់ទុកជាការផ្ទេរកម្មសិទ្ធិទ្រព្យសម្បត្តិនោះពេញលេញជាលក្ខណៈ ច្បាប់បានឡើយ។

តាមក្រមរដ្ឋប្បវេណីថ្មីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៣៤ និង១៣៥ បានកំណត់អំពីលក្ខខណ្ឌនៃការតតាំងចំពោះសិទ្ធិប្រត្យក្ស គឺទាល់តែមានការចុះបញ្ជីទើបតតិយជនមិនអាចជំទាស់បានចំពោះអចលនវត្ថុ ចំណែកឯកចលនវត្ថុវិញចាប់ពីពេលដែលមានការប្រគល់ចលនវត្ថុនោះដល់ភាគីម្ខាងទៀត[18]។

តាមមាត្រា ៣៣៦ កថាខណ្ឌ ២ បានចែងថាកិច្ចសន្យាដែលភាគីម្ខាងទទួលក្នុងករណីកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត។ ដូចនេះកិច្ចសន្យាទិញលក់អចលនវត្ថុត្រូវតែធ្វើតាមលិខិតយថាភូត បើមិនដូច្នោះទេកិច្ចសន្យានោះនិងត្រូវទុកជាមោឃៈ ព្រោះបញ្ញត្តិដែលមានចែងក្នុង មាត្រា៣៣៦ នេះជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ។ តាមមាត្រា ៣៥៧ ប្រសិនបើសកម្មភាពនោះបានផ្ទុយ នឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំត្រូវចាត់ទុកជាមោឃៈ[19]។

នៅក្នុងលក្ខខណ្ឌកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកគឺ ម្ចាស់ម៉ាកអាចធ្វើការលក់ ឬ ជួលម៉ាករបស់ខ្លួនទៅឱ្យតតិយជន។ ចំពោះការលក់ម៉ាករបស់ខ្លួនទៅឱ្យតតិយជននេះដែរ គឺម្ចាស់កម្មសិទ្ធិករអាចធ្វើការផ្ទេរសិទ្ធិរបស់ខ្លួនតាមរយៈកិច្ចសន្យាអនុប្បទាន។ កិច្ចសន្យាអនុប្បទាន គឺជាកិច្ចសន្យាមួយដែលម្ចាស់ម៉ាក(អនុប្បទាយី) យល់ព្រមផ្ទេរសិទ្ធិកម្មសិទ្ធិទៅឱ្យអ្នកទទួលសិទ្ធិ(អនុប្បទានិក) ហើយអ្នកទទួលសិទ្ធិនិងក្លាយជាកម្មសិទ្ធិករលើម៉ាកនោះ។

ក្នុងក្របខណ្ឌច្បាប់ជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ពុំមានបទប្បញ្ញត្តិកំណត់អំពីសញ្ញាណនៃការ

---

[16] ដដែល, ទំព័រ១៥។

[17] ព្រះរាជក្រឹត្យច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី,លេខ នស/រកម/១៥១១/00៧, ០៩ ឧសភា ២០១១, មាត្រា៩។

[18] ដូច7, ទំព័រ១៦។

[19] ដដែល, ទំព័រ១៦។

កិច្ចសន្យាអនុប្បទានឡើយ។ ចំពោះសញ្ញាណនៃកិច្ចសន្យាអនុប្បទានគឺត្រូវធ្វើការវែកញែកដោយនីតិវិទូ ដោយប្រដូចទៅនឹងកិច្ចសន្យាទិញលក់ដោយផ្អែកលើប្រតិបត្តិការ ឬការអនុវត្តនៃកិច្ចសន្យាកិច្ចសន្យាទាំងពីរ[20]។

ចំពោះក្នុងប្រតិបត្តិការនៃកិច្ចសន្យាអនុប្បទាន អនុប្បទាយី (ម្ចាស់កម្មសិទ្ធិ) មានករណីកិច្ចត្រូវប្រគល់សិទ្ធិឱ្យទៅអនុប្បទានិក (អ្នកទទួលសិទ្ធិ) ហើយអនុប្បទានិកមានករណីកិច្ចត្រូវបង់ប្រាក់ថ្លៃឱ្យទៅអនុប្បទាយីវិញ។ ហើយអ្វីដែលខុសគ្នាចំពោះកិច្ចសន្យាទិញលក់ និងកិច្ចសន្យាអនុប្បទាន គឺកម្មវត្ថុនៃកិច្ចសន្យាដែលកិច្ចសន្យាទិញលក់មានកម្មវត្ថុជាទ្រព្យរូបិយ(ចលនទ្រព្យ ឬអចលនទ្រព្យ) ចំណែកឯកិច្ចសន្យាអនុប្បទានវិញគឺមានកម្មវត្ថុជាទ្រព្យអរូបិយ(សិទ្ធិលើម៉ាក)[21]។

## ១.៣. លក្ខខណ្ឌផ្លូវច្បាប់ក្នុងការបង្កើតកិច្ចសន្យាអនុប្បទាន

នៅក្នុងកិច្ចសន្យាអនុប្បទានលក្ខខណ្ឌគ្រឹះនៃការបង្កើតកិច្ចសន្យាត្រូវអនុវត្តៈ ឆន្ទៈរបស់ភាគី សមត្ថភាពនៃភាគីនៃកិច្ចសន្យា កម្មវត្ថុនៃកិច្ចសន្យា និងតម្លៃ។

<u>គោលការណ៍ស្វ័យភាពក្នុងការបង្ហាញឆន្ទៈ៖</u> ឆន្ទៈរបស់គូភាគីត្រូវបង្ហាញឡើងក្នុងគោលដៅបង្កើតកិច្ចសន្យាដោយជៀសផុតពីវិការៈនៃការបង្ហាញឆន្ទៈ(ការភ័ន្តច្រឡំ ការឆបោក ការគេងចំនេញហួសហេតុ)[22]។

<u>សមត្ថភាព៖</u> បន្ថែមលើអត្ថន័យក្នុងកិច្ចសន្យាទូទៅ សមត្ថភាពមិនត្រឹមតែសម្តៅទៅលើនីតិភាពនៃភាគីប៉ុណ្ណោះទេ ប៉ុន្តែតម្រូវឱ្យអនុប្បទាយីជាម្ចាស់សិទ្ធិស្របច្បាប់នៃម៉ាកនោះ។ នៅក្នុងករណីម៉ាកដែលមានម្ចាស់សិទ្ធិច្រើន កិច្ចសន្យាអាចធ្វើឡើងបាន លុះត្រាតែមានការយល់ព្រមពីម្ចាស់សិទ្ធិទាំអស់ជាមុនសិន[23]។

<u>កម្មវត្ថុ៖</u> ជាគោលការណកម្មវត្ថុនៃកិច្ចសន្យាត្រូវតែមានវត្តមាននៅពេលបង្កើតកិច្ចសន្យា ឬអាចនឹងកើតមាននាពេលអនាគត។ ប្រសិនបើសិទ្ធិលើម៉ាកត្រូវផុតអាជ្ញាយុកាលការពារ ឬមិនត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីកិច្ចសន្យានោះមិនត្រូវចាត់ទុកថាមានសុពលភាពឡើយ។ ក្នុងករណីដែលមានម៉ាកច្រើនដែលជាកម្មវត្ថុនៃកិច្ចសន្យា ការលុបចោល ឬការផុតអាជ្ញាយុកាលនៃម៉ាកណាមួយ នឹងមិនមានអានុភាពលុបកិច្ចសន្យាទាំងមូលឡើយ[24]។

<u>តម្លៃ៖</u> នៅក្នុងកិច្ចសន្យាអនុប្បទានគឺត្រូវកំណត់តម្លៃឱ្យជាក់លាក់ ភាគីអាចកំណត់ចំនួនតម្លៃនៃកម្មវត្ថុនៃកិច្ចសន្យាដោយផ្អែកលើតម្លៃទីផ្សារបច្ចុប្បន្ន ឬ នាពេលអនាគត ឬ ដោយផ្អែកលើការវាយតម្លៃរបស់តតិយជន។ ការអវត្តមាននៃការកំណត់តម្លៃគឺមិនអាចធ្វើឱ្យកិច្ចសន្យានេះមិនមានសុពលភាពឡើយ មិនតែ

---

[20] ដូច2, ទំព័រ១៣៧។

[21] ដដែល, ទំព័រ១៣៧។

[22] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រ៣៤៥-៣៤៧ និងមាត្រា៣៥១។

[23] ដូច2, ទំព័រ១៣៨។

[24] ដដែល, ទំព័រ១៣៨។

ប៉ុណ្ណោះភាគីអាចកំណត់អំពីមធ្យោបាយនៃការបង់ថ្លៃដោយបង់តម្លៃសរុបតាមតម្លៃពិត ឬ បង់ធនលាភមកអនុប្បទាយី[25]។

### ១.៤. លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាអនុប្បទាន

រាល់កិច្ចសន្យាផ្ទេរសិទ្ធិម៉ាក ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវដាក់ជូនដំណឹងទៅកាន់មន្ត្រីកាន់កាប់បញ្ជីដើម្បីកត់ត្រាការផ្ទេរសិទ្ធិ ឬ ការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិនោះ។ កិច្ចសន្យានេះនឹងពុំមានអានុភាពតតាំងជាមួយតតិយជនឡើយប្រសិនបើពុំបានកត់ត្រានៅមន្ត្រីកាន់កាប់បញ្ជីទេ។ ការប្តូរម្ចាស់កម្មសិទ្ធិនឹងមានអានុភាពចំពោះតតិយជននៅពេលដែលការកត់ត្រាចូលបញ្ជីត្រូវបានធ្វើរួចរាល់[26]។

## កថាខណ្ឌទី២៖ កិច្ចសន្យាជួលម៉ាក

កិច្ចសន្យាជួលម៉ាកគឺភាគច្រើនគេអនុវត្តតាមវិធានបញ្ញត្តិនៃនីតិរួម គឺដូចគ្នាទៅនឹងកិច្ចសន្យាជួលដែរ ដូចនេះបើយើងនិយាយាពីកិច្ចសន្យាជួលក្នុងក្រមរដ្ឋប្បវេណី គឺយើងអាចនឹកដល់ភតិសន្យា។

ភិតិសន្យាសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងឱ្យភាគីម្ខាងទៀតប្រើប្រាស់និង អាស្រ័យផលពីវត្ថុណាមួយដោយយកថ្លៃ។ វត្ថុដែលជាកម្មវត្ថុនៃភតិសន្យាមានចលនវត្ថុនិងអចលនវត្ថុ[27]។

ភតិសន្យាត្រូវមានអនុភាពដោយភាគីម្ខាងសន្យាថាឱ្យភាគីម្ខាងទៀងប្រើប្រាស់ និងអាស្រ័យផលពីវត្ថុណាមួយចំណែកឯភាគីម្ខាងទៀតសន្យាថាបង់ថ្លៃឈ្នួលចំពោះវត្ថុនោះ[28]។

តាមក្រមរដ្ឋប្បវេណីសង្គមចាស់១៩៦៧ មាត្រា១០៩៩ មានអោយអត្ថន័យថាកិច្ចសន្យាជួលជាកិច្ចសន្យាដែលជនណាម្នាក់សន្យាថានឹងផ្តល់ទៅឱ្យជនណាម្នាក់ទៀតនូវវត្ថុណាមួយដើម្បីប្រើប្រាស់ ក្នុងពេលមានកំណត់ដោយឱ្យថ្លៃតាមសមាមាត្រនៃពេល[29]។

### ២. លក្ខខណ្ឌតតាំងនៃភតិសន្យា

លក្ខខណ្ឌតតាំងជាលក្ខខណ្ឌមួយដែលកំណត់ដោយច្បាប់ ដើម្បីអាចតតាំងជាមួយតតិយជនបានលុះត្រាភាគីត្រូវតែបំពេញលក្ខខណ្ឌទាំងនេះ។

ចំពោះលក្ខខណ្ឌតតាំងមិនជាលក្ខខណ្ឌសុពលភាពនៃកិច្ចសន្យានោះទេ តែវាជាលក្ខខណ្ឌដែល

---

[25] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៥២១។

[26] ដូច2, ទំព័រ១៣៩។

[27] ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧, មាត្រា៥៩៦, ច្បាប់ភូមិបាល, លេខ នស/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា១០៦ (ពីពេលនេះតទៅហៅថា ច្បាប់ភូមិបាលឆ្នាំ២០០១)។

[28] ដូច7, ទំព័រ៤៩។

[29] ដដែល, ទំព័រ៤៩។

អនុញ្ញាត្តអោយគូភាគីអាចយកមកតតាំងចំពោះតតិយជនទុច្ចរិត ដែលមកអះអាងនៅសិទ្ធិរបស់ខ្លួនចំពោះវត្ថុដែលបានប្រគល់នោះ[30]។

តាមមាត្រា១៣៥នៃក្រមរដ្ឋប្បវេណី ការផ្ទេរសិទ្ធិលើអចលនវត្ថុដែលមានអនុភាពពេញលេញហើយយកទៅតតាំងបានចំពោះគ្រប់តតិយជននោះទាល់តែការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ ត្រូវធ្វើការចុះបញ្ជីអោយស្របតាមបញ្ញត្តិរបស់ច្បាប់។ តាមមាត្រានេះមានន័យថាការទិញលក់អចលនវត្ថុដោយគ្រាន់តែធ្វើឡើងតាមការព្រមព្រៀងវាមានសុពលភាពតែមិនអាចកិច្ចសន្យានោះទៅធ្វើការតតាំង ឬអះអាងចំពោះតតិយជន ដែលបានមកធ្វើការទាមទារសិទ្ធិរបស់ខ្លួនចំពោះវត្ថុនោះបានឡើយ[31]។

### ២.១. លក្ខខណ្ឌតតាំងនៃសិទ្ធិជួលអចលនវត្ថុ

ភតិសន្យាគឺគ្រាន់តែជាកិច្ចសន្យាមួយដែលភតិកៈអាចអះអាងពីសិទ្ធិប្រើប្រាស់ និងអាស្រ័យផលរបស់ខ្លួនបានតែចំពោះភតិបតីប៉ុណ្ណោះ។ ភតិកៈដែលកំពុងតែកាន់កាប់វត្ថុជួលអាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញសិទ្ធិទាមទារឱ្យប្រគល់វិញសិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង និងសិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំងចំពោះការបំពានសិទ្ធិជួលដូចសិទ្ធិដែលកម្មសិទ្ធករមាន[32]។

- **រយៈពេលនៃភតិសន្យា**

ភតិសន្យាអាចធ្វើឡើងដោយកំណត់ឬមិនកំណត់អឡ្សុងពេលបាន។ ភតិសន្យាអចលនវត្ថុដែលមិនបានធ្វើជាលាយលក្ខ័អក្សរត្រូវចាត់ទុកថាជាជតិសន្យាដែលគ្មានកំណត់អំឡុងពេល[33]។

ភតិសន្យាគ្មានកំណត់អំឡុងពេលគឺតយៈពេលនៃការជួលមិនអាចលើសពី១៥ឆ្នាំទេ។ ដូច្នេះភតិសន្យាមិនមានកំពត់រយៈពេលជានិរន្តន៍ឬអស់មួយជីវិតបានទេ នៅក្នុងករណីបើមានការចែងថាភតិសន្យាមានរយៈពេលជានិរន្តន៍កិច្ចសន្យានោះត្រូវចាត់ទុកជាមោឃៈ[34]។

កិច្ចសន្យាជួលមិនមានរយៈពេលកំណត់គឺអាចបន្តការជួលរយៈពេលសាជាថ្មីបាន ដោយបង្កើតបានជាទំនាក់ទំនងផ្ទាល់ខ្លួនរវាងភតិសន្យាបតីនិងអ្នកជួល[35]។ កិច្ចសន្យាជួលរយៈពេលខ្លីគឺអាចបន្តជួលជាថ្មីបានបង្កើតបានជាទំនាក់ទំនងផ្ទាល់ខ្លួន រវាងភតិបតីនិងអ្នកជួល។ ការជួលអចលនវត្ថុដែលមានកំណត់អំឡុងពេលចាប់ពី១៥ឆ្នាំឡើងទៅត្រូវយកទៅចុះបញ្ជីប្រសិនបើមិនបានយកទៅចុះបញ្ជីទេ នោះការ

---

[30] ដដែល, ទំព័រ៤៩។

[31] ដដែល, ទំព័រ៤៩។

[32] ដដែល, ទំព័រ៤៩។

[33] ដដែល, ទំព័រ៥០។

[34] ដដែល, ទំព័រ៥០។

[35] ដដែល, ទំព័រ៥០។

ជួលនោះមានអានុភាពជាកិច្ចសន្យាជួលមានរយៈពេល១៥ឆ្នាំ[36]។

សម្រាប់ភតិសន្យាអចលនវត្ថុដែលមានកំណត់អំឡុងពេលគិតចាប់ពី ១៥ឆ្នាំ ឡើងទៅគឺ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

**-លក្ខខណ្ឌគ្រឹះនៃការបង្កើតភតិសន្យា**

លក្ខខណ្ឌគ្រឹះជាលក្ខខណ្ឌដែលកំណត់ដោយច្បាប់ ហើយបើគូភាគីមិនបានបំពេញលក្ខខណ្ឌនោះទេវានាំអោយកិច្ចសន្យានោះគ្មានសុពលភាពបានឡើយ។ គេអាចនិយាយបានថាលក្ខខណ្ឌគ្រឹះជាបទបញ្ញត្តិដោយបង្ខំ ព្រោះច្បាប់មិនអនុញ្ញាតអោយមានការព្រមព្រៀងណាធ្វើឡើយផ្ទុយពីបទបញ្ញត្តិនេះបានឡើយ។

ដើម្បីអោយកិច្ចសន្យាមួយមានសុពលភាព ទាល់តែកិច្ចសន្យានោះកើតចេញពីការព្រមព្រៀងដោយសេរី និងពិតប្រាកដកើតពីបុគ្គលដែលមានសមត្ថភាព និងមានកម្មវត្ថុស្របច្បាប់។ តាមមាត្រានេះ មានន័យថាគ្មានកិច្ចសន្យាណាមួយមានសុពលភាពបានឡើយ បើកិច្ចសន្យានោះមានបំពេញតាមលក្ខខណ្ឌដែលបានកំណត់នេះដែលនេះគេហៅថាលក្ខខណ្ឌគ្រឹះ[37]។ កិច្ចសន្យាគឺជាឆន្ទៈព្រមព្រៀងរវាងបុគ្គលពីរនាក់ ឬច្រើននាក់ ដើម្បីបង្កើតកែប្រែឬរលត់កាតព្វកិច្ចមួយឬច្រើនដែលទាក់ទងនឹងខ្លួន[38]។

**ក.ការព្រមព្រៀងពិតប្រាកដនិងសេរី**

កិច្ចសន្យាដែលកើតចេញពីការព្រមព្រៀងពិតប្រាកដនិងសេរីមានន័យថា កិច្ចសន្យានោះធ្វើឡើងដោយភាគីទាំងពីរបានព្រមព្រៀងគ្នាដោយគ្មានការប្រើអំពើហិង្សាបន្លំបោកប្រាស់និងភ័ន្តច្រឡំទេ។ នៅក្នុងករណីបើកិច្ចសន្យាណាមួយដែលកើតពីការព្រមព្រៀងមិនត្រឹមត្រូវឬពិតប្រាកដនិងមិនដោយសេរីទេកិច្ចសន្យានោះត្រូគិតជាមោឃៈដាច់ខាត[39]។

**ខ. អំពើហិង្សា**

អពើហិង្សាគឺជាការប្រើអំពើណាមួយដែលបង្ខំទៅលើរូបរាងកាយ ឬ ផ្លូវចិត្តទៅបុគ្គលណាមួយដើម្បីឱ្យមានការចុះកិច្ចសន្យា។ ដូច្នេះអំពើហិង្សាដែលជាមូលហេតុមោឃៈភាពនៃកិច្ចសន្យាបាន កាលណាអំពើហិង្សានោះជាការគំរាមកំហែងនិងបង្ខិតបង្ខំតាមផ្លូវកាយឬផ្លូវចិត្តប្រព្រឹត្តទៅលើភាគីណាមួយ[40]។

**គ. ការបន្លំបោកប្រាស់**

ការបន្លំបោកប្រាស់គឺជាមូលហេតុនៃមោឃភាពកិច្ចសន្យាកាលណាមានការប្រើ ឧបាយកលអំពើបោក

[36] ដដែល, ទំព័រ៥០។

[37] ដដែល, ទំព័រ៥០។

[38] ដដែល, ទំព័រ៥០។

[39] ដដែល, ទំព័រ៥១។

[40] ដដែល, ទំព័រ៥១។

បញ្ឆោត អំពើបន្លំភូតកុហកប្រព្រឹត្តដោយភាគីណាមួយដែលមានហេតុផលជាក់ច្បាស់ថា បើគ្មានកិច្ចកលទាំងនោះទេនោះភាគីម្ខាងទៀតប្រាកដជាមិនអាចធ្វើកិច្ចសន្យានោះឡើយ[41]។

**ឃ. ការភាន់ច្រឡំ**

គ្រប់ករណីភ័ន្តច្រឡំមិនមែនសុទ្ធតែជាវិការៈនៃការព្រមព្រៀង ដែលធ្វើឱ្យកិច្ចសន្យាមោឃភាពនោះទេ។ ការភាន់ច្រឡំដែលជាមូលហេតុបោយភាពនៃកិច្ចសន្យា លុះត្រាតែការភ័ន្តច្រឡំទៅលើសារជាតិនៃរបស់ដែលជាកម្មវត្ថុដែលជាកម្មវត្ថុកិច្ចសន្យា[42]។

**ខ. សមត្ថភាពរបស់ភាគី**

ជនដែលមានអាយុគ្រប់១៨ឆ្នាំ ដែលច្បាប់ហៅថានីតិជនអាចធ្វើកិច្ចសន្យាបានគ្រប់ពេលវេលាទាំងអស់ ពីព្រោះជននេះច្បាប់បានប្រគល់សិទ្ធិ និងទទួលនូវកាតព្វកិច្ចសំរាប់អនុវត្តន៍នៅក្នុងជីវភាពរស់នៅ[43]។

អនីតិជនមានអាយុក្រោម១៨ឆ្នាំជាអសមត្ថជន មិនអាចធ្វើឱ្យកើតសិទ្ធិឬករណីកិច្ចនានា ជាពិសេសមិនអាចចុះកិច្ចសន្យាដោយគ្មានការយល់ព្រមពីអាណាព្យាបាលស្របច្បាប់របស់ខ្លួនបានឡើយ។ កិច្ចសន្យាដែលធ្វើដោយនីតិជនដោយគ្មានការយល់ព្រមពីអាណាព្យាបាលនៅមុនពេលចុះកិច្ចសន្យា នឹងអាចយកទៅអនុវត្តបានលុះត្រាតែអាណាព្យាបាលបានឯកភាពលើកិច្ចសន្យានោះក្រោយពេលដែលអនីតិជននោះចុះកិច្ចសន្យារួច។

ដូច្នេះភាគីដែលចុះកិច្ចសន្យាជាមួយជនដែលអសមត្ថភាពមិនអាចដោះសារដើម្បីគេចកែពីកាតព្វកិច្ចនៃកិច្ចសន្យាជាមួយនឹងខ្លួនជាអសមត្ថជនបានឡើយ។ សរុបមកគ្រប់បុគ្គលដែលមានអាយុ១៨ឆ្នាំច្បាប់បានកំណត់ថាជានីតិជនដែលមានសមត្ថភាព លើកលែងតែជនគំហាត់ដែលច្បាប់បានកំណត់ថាជនទាំងនោះជាសមត្ថជនទោះបីជាជននោះមានអាយុគ្រប់១៨ឆ្នាំក៏ដោយក៏មិនអាចចុះកិច្ចសន្យាដែរ[44]។

**សមត្ថភាពភតិបតីដែលអាចជួលវត្ថុបានលុះត្រាតែជា៖**

ក. កម្មសិទ្ធិនៃវត្ថុ៖កម្មសិទ្ធិនៃទ្រព្យអាចជួលទ្រព្យខ្លួនដោយសេរី។

ខ. ផលុបភោគី៖ផលុបភោគី៖ ផលុបភោគីអាចធ្វើការជួលនូវទ្រព្យសម្បត្តិ ដែលខ្លួនអាស្រ័យផលនោះបាន ប៉ុន្តែការជួលនេះមិនត្រូវធ្វើកិច្ចសន្យាឱ្យហួសរយៈពេល៣ឆ្នាំឡើយ។ ក្នុងករណីបើផលុបភោគីចង់បន្តជួលនូវទ្រព្យសម្បត្តិដែលខ្លួនអាស្រ័យផលកិច្ចសន្យាជួលថ្មីនោះ ត្រូវតែបញ្ចប់មុនពេលមួយឆ្នាំនៃថ្ងៃចប់កិច្ចសន្យាផលុបភោគ។

---

[41] ដដែល, ទំព័រ៥១។

[42] ដដែល, ទំព័រ៥២។

[43] ដដែល, ទំព័រ៥២។

[44] ដដែល, ទំព័រ៥២។

គ. ភតិកៈប្រសិនបើមានការព្រមព្រៀងឬអនុញ្ញាតពីកម្មសិទ្ធិករ៖ ភតិកៈអាចជួលទ្រព្យសម្បត្តិ ឬ វត្ថុដែលខ្លួនជួលនោះលុះត្រាតែមានការព្រមព្រៀងដោយជាក់លាក់ឬអនុញ្ញាតពីកម្មសិទ្ធិករឬ អ្នកជួល។ ភតិកៈត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការបំពេញលិខិតគតិយុត្តិមានន័យថាជាបុគ្គលដែលជនមាន អាយុ១៨ ឆ្នាំតាមច្បាប់កំណត់ ប៉ុន្តែមិនមែនជាជនហាត់ដែលច្បាប់បានចាត់ទុកជាជនអសមត្ថភាពនេះទេ[45]។

➢ **កម្មវត្ថុនៃភតិសន្យា**

**កម្មវត្ថុនៃកិច្ចសន្យាជួលមានដូចខាងក្រោម៖**

វត្ថុ៖ វត្ថុក្នុងកិច្ចសន្យាជួលក៏ដូចជាវត្ថុក្នុងកិច្ចសន្យាដទៃទៀតដែរត្រូវតែជាវត្ថុមួយដែលជាក់លាក់អាចធ្វើកើតស្របច្បាប់និងរបៀបរៀបរយសាធារណៈ ឬ ទំនៀមទំលាប់ល្អប្រពៃ។ វត្ថុត្រូវតែជាវត្ថុដែលស្ថិតក្នុងពាណិជ្ជកម្មមិនអាចកើត ឬស្របច្បាប់របៀបរៀបរយសាធារណៈ និងទំនៀមទំលាប់ប្រពៃណីនោះកិច្ចសន្យាជួលដែលត្រូវបានធ្វើឡើងត្រូវចាត់ទុកជាមោឃៈ[46]។

វត្ថុក្នុងកិច្ចសន្យាជួលមានពីរប្រភេទដូចខាងក្រោម៖

- ◆ ចលនវត្ថុ៖គឺជាវត្ថុដែលអាចផ្លាស់ប្តូរទីកន្លែងបាន។ ឧ. កង ម៉ូតូ ឡាន សៀវភៅ តុ កៅអី ជាដើម។ល។
- ◆ អចលនវត្ថុ៖គឺជាវត្ថុដែលមានស្ថានភាពជាប់នឹងកន្លែងតែមួយកំរើកមិនកើត ឬ មិនអាចផ្លាស់ប្តូរទីកន្លែងបាន។ ឧ. ដី ផ្ទះ អគារ សំណង់ ជាដើម។ល។

ក្នុងក្រមរដ្ឋប្បវេណីភតិសន្យាសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងឱ្យភាគីម្ខាងទៀតប្រើប្រាស់ និង អាស្រ័យផលពីវត្ថុណាមួយដោយយកថ្លៃ។ វត្ថុដែលជាកម្មវត្ថុនៃភតិសន្យាមានចលនវត្ថុ និង អចលនវត្ថុ។ ម្ចាស់អចលនវត្ថុឬចលនវត្ថុដែលដាក់ជូនឱ្យអ្នកដទៃគឺហៅថាភតិបតី និងអ្នកជួលចលនវត្ថុ ឬ អចលនវត្ថុហៅថាភតិកៈ[47]។

សរុបមកយើងឃើញថាច្បាប់ទាំងបីគឺ ក្រឹត្យច្បាប់លេខ៣៨ភូមិបាលឆ្នាំ២០០១ និងក្រមរដ្ឋប្បវេណីមានភាពខុសប្លែកគ្នាក្នុងការប្រើប្រាស់ពាក្យបច្ចេកទេសក្នុងការហៅកិច្ចសន្យានេះ[48]។

ប្រាក់ឈ្នួល៖ គឺជាធាតុសំខាន់ក្នុងកិច្ចសន្យាជួលពីព្រោះថាមិនមែនជាកិច្ចសន្យាជួលនោះទេប្រសិនបើការជួលនោះមិនបានយកឈ្នួលលើវត្ថុដែលដាក់ជួលនោះ។ កាលណាបើយើងឱ្យវត្ថុប្រើប្រាស់ជនណាម្នាក់

[45] ដដែល, ទំព័រ៥២។

[46] ដដែល, ទំព័រ៥៣។

[47] ដដែល, ទំព័រ៥៣។

[48] ដដែល, ទំព័រ៥៤។

ដោយមិនបានយកប្រាក់ឈ្នួលឬកំរៃលើវត្ថុនោះគឺជាការឱ្យខ្ចីទៅវិញ។ នៅក្នុងច្បាប់មិនបានចែងឬកំណត់ឱ្យបានច្បាស់លាស់អំពីប្រាក់ឈ្នួលនោះទេ ដូច្នេះគូភាគីនៃកិច្ចសន្យាជួលមានសិទ្ធិសេរីភាពពេញលេញក្នុងការកំណត់ប្រាក់ឈ្នួល និងរយៈពេលនៃការកំណត់ប្រាក់ឈ្នួលនៅក្នុងកិច្ចសន្យាដែលបានព្រមព្រៀងជាមួយគ្នា[49]។

-ជាទូទៅប្រាក់ឈ្នួលដែលបានមកពីការជួលអចលនវត្ថុឬចលនវត្ថុអាចគិតជាទឹកប្រាក់ឬវត្ថុណាមួយដែលមានតំលៃស្មើ។

-ចំពោះការបង់ប្រាក់ឈ្នួលវិញ គឺអាចបង់ជាម៉ោង ជាថ្ងៃ ជាអាទិត្យ ជាខែ ជាឆ្នាំ ឬ បង់ផ្តាច់តែម្តងក៏បាន។

-ក្នុងករណីកិច្ចសន្យាមិនបានកំណត់ពេលវេលានៃការបង់ប្រាក់ឈ្នួល ចំពោះចលនវត្ថុនិងផ្ទះ ឬ អគារត្រូវបង់ជារៀងរាល់ចុងខែ។ រីឯចំពោះដីធ្លីវិញត្រូវបង់នៅរៀងរាល់ចយងឆ្នាំ។ ប៉ុន្តែចំពោះវត្ថុដែលមានរដូវប្រមូលផលត្រូវបង់នៅពេលដែលរដូវប្រមូលផលនោះកន្លងផុតទៅដោយគ្មានការយឺតយ៉ាវ។

### ២.២. លក្ខខណ្ឌទម្រង់នៃភតិសន្យា

លក្ខខណ្ឌទម្រង់នៃកិច្ចសន្យាជួលមានសារសំខាន់ណាស់ ដែលតម្រូវឱ្យភាគីនីមួយៗគោរពតាមនិងប្រតិបត្តិតាមច្បាប់ជាធរមាន ពីព្រោះថានៅពេលភាគីមិនគោរពកិច្ចសន្យា ឬ ធ្វេសប្រហែសមិនបានបំពេញតាមទម្រង់ត្រឹមត្រូវនោះអាចជាកត្តាមួយដែលនាំឱ្យគូភាគីនៃកិច្ចសន្យាខូចប្រយោជន៍ជាមិនខាន។ ម្យ៉ាងវិញទៀតការកំណត់ទម្រង់នៃកិច្ចសន្យាជួលគឺ មានភាពពាក់ព័ន្ធនឹងលក្ខខណ្ឌសុពលភាពរបស់កិច្ចសន្យានេះដែរ[50]។

ប្រសិនបើកិច្ចសន្យាជួលអចលនវត្ថុធ្វើឡើងដោយគ្មានសំបុត្រស្នាម ឬ ជាលាយលក្ខណ៍អក្សរបាននោះទេភាគីម្ខាងប្រកែកបន្ទាល់ការជួលអចលនវត្ថុនេះនឹងយកសំអាងសាក្សីមកបញ្ជាក់ លុះត្រាតែកិច្ចសន្យានៃការជួលនោះមានរយៈពេលត្រឹមតែមួយឆ្នាំប៉ុណ្ណោះ។ ដូច្នេះកិច្ចសន្យាជួលអចលនវត្ថុមានរយៈពេលកំណត់លើសពីមួយឆ្នាំឡើងទៅ ដែលមិនបានធ្វើជាលាយលក្ខណ៍អក្សរ ប្រសិនបើភាគីណាមួយចង់ប្រកែក ឬកែប្រែនោះភាគីម្ខាងទៀតមិនអាចយកសាក្សីមកសំអាងលើការជួលនោះទេ[51]។

ក្រមរដ្ឋប្បវេណីមិនបានចែងពីលក្ខខណ្ឌទម្រង់នៃកិច្ចសន្យាជួលអចលនវត្ថុទេ ដូច្នេះយើងមិនដឹងថាកិច្ចសន្យាជួលអចលនវត្ថុត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ ឬអាចធ្វើផ្ទាល់មាត់ដោយមិនធ្វើលិខិតស្នាមក៏បាន[52]។

#### ❖ កិច្ចសន្យាជួលអចលនវត្ថុ

តាមច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា១០៩ វាក្យខណ្ឌ២បានចែងថាកិច្ចសន្យាជួលអចលនវត្ថុ ឬភតិសន្យាគឺត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ហើយភតិសន្យាដែលធ្វើឡើងដោយផ្ទាល់មាត់ គឺត្រូវចាត់

---

[49] ដដែល, ទំព័រ៥៤។

[50] ដដែល, ទំព័រ៥៤។

[51] ដដែល, ទំព័រ៥៥។

[52] ដដែល, ទំព័រ៥៥។

ទុកជាបណ្តោះអាសន្ន ហើយត្រូវបានបញ្ឈប់នៅគ្រប់ពេលដោយជូនដំណឹងក្នុងរយៈពេលស្មើនឹងរយៈពេលបង់ប្រាក់ឈ្នួល[53]។

តាមច្បាប់ភូមិបាលឆ្នាំ២០០១ មាត្រាខាងលើកិច្ចសន្យាជួលអចលនវត្ថុមិនមែនជាកិច្ចសន្យាឱឡារិកនោះទេ ពីព្រោះច្បាប់មិនតម្រូវឱ្យធ្វើជាលាយលក្ខណ៍អក្សរដើម្បីធ្វើឱ្យមានសុពលភាពទេ។ ដូច្នេះកិច្ចសន្យាជួលអចលនវត្ថុអាចធ្វើជាលាយលក្ខណ៍អក្សរ ឬធ្វើផ្ទាល់មាត់(មិនធ្វើជាលាយលក្ខណ៍អក្សរ)ក៏បាន ប៉ុន្តែបើភាគីជ្រើសរើសយកកិច្ចសន្យាមិនលាយលក្ខណ៍អក្សរ នោះនឹងធ្វើឱ្យកិច្ចសន្យាជួលនោះមានលក្ខណៈផុយស្រួយ ឬងាយនឹងឱ្យភាគីម្ខាងទៀតបញ្ចប់កិច្ចសន្យាដោយសេរី ដែលបណ្តាលឱ្យមានការខូចប្រយោជន៍ជាច្រើន[54]។

ចំពោះក្រមរដ្ឋប្បវេណី មាត្រា៥៩៦ ចំនុចទី២ វិញភតិសន្យាអចលនវត្ថុដែលមិនបានធ្វើជាលាយលក្ខណ៍អក្សរត្រូវបានចាត់ទុកជា ភតិសន្យាដែលគ្មានកំណត់កំឡុងពេល។

កិច្ចសន្យាជួលអាចអចលនវត្ថុមិនមានកំណត់រយៈពេល កិច្ចសន្យាជួលនោះ នឹងត្រូវបានរំលាយនៅពេលណាក៏បាន នៅពេលភាគីណាមួយរំលាយកិច្ចសន្យា[55]។

តាមច្បាប់ភូមិបាល ឆ្នាំ២០០១ និងក្រមរដ្ឋប្បវេណី មានភាពខុសពីព្រោះ បើច្បាប់ភូមិបាលឆ្នាំ ២០០១ ភតិសន្យាដែលមិនបានធ្វើជាលាយលក្ខណ៍អក្សរត្រូវទុកជា បណ្តោះអាសន្នហើយអាចត្រូវបានបញ្ចប់នៅគ្រប់ពេល ដោយជូនដំណឹងជាមុនក្នុងរយៈពេលបង់ប្រាក់ឈ្នួល ប៉ុន្តែតាមក្រមរដ្ឋប្បវេណី គឺភតិសន្យាដែលមិនបានធ្វើជាលាយលក្ខណ៍ ត្រូវចាត់ទុកជាភតិសន្យា ដែលគ្មានកំណត់រយៈពេល ដែលកិច្ចសន្យាត្រូវរំលាយពេលណាក៏បាន នៅពេលភាគីណារំលាយកិច្ចសន្យា។ ម្យ៉ាងវិញទៀត នៅក្នុងក្រមរដ្ឋប្បវេណីនេះដែរ ភតិសន្យាអចលនវត្ថុដែលមានថែងក្នុងរយៈពេលចាប់ពី ១៥ឆ្នាំ ឡើងទៅត្រូវចុះបញ្ជី តែបើមិនបានចុះបញ្ជីត្រូវមានអនុភាព ភតិសន្យារហូតដល់គ្រប់កំឡុងពេល ១៥ឆ្នាំប៉ុណ្ណោះ[56]។

ចំពោះកិច្ចសន្យាជួលម៉ាកវិញ គឺជាកិច្ចសន្យាមួយដែលអនុញ្ញាតឱ្យម្ចាស់ម៉ាក(អ្នកផ្តល់អាជ្ញាប័ណ្ណ) ផ្ទេរទៅឱ្យតតិយជន(អ្នកទទួលអាជ្ញាប័ណ្ណ) ដើម្បីអនុវត្តសិទ្ធិសេដ្ឋកិច្ចលើម៉ាកនៅក្នុងលក្ខខណ្ឌ និងរយៈពេលជាក់លាក់ ហើយម្ចាស់ម៉ាកនៅតែជាម្ចាស់កម្មសិទ្ធិករលើម៉ាកដដែល។ កិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកជាប្រភេទនៃកិច្ចសន្យាពិសេសនានាដែលពុំមានអានុភាពផ្ទេរសិទ្ធិកម្មសិទ្ធិទាំងស្រុងទៅឱ្យតតិយជនឡើយ។

ដើម្បីយល់អំពីកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក គេអាចប្រៀបធៀបប្រតិបត្តិការនៃកិច្ចសន្យានេះ ទៅនឹង

---

53 ដដែល, ទំព័រ៥៥។

54 ដដែល, ទំព័រ៥៥។

55 ដដែល, ទំព័រ៥៦។

56 ដដែល, ទំព័រ៥៦។

កិច្ចសន្យាជួលដូចដែលបានរៀបរាប់ខាងលើនេះ[57]។

## ២.៣. «ខ»ពិសេសក្នុងការបង្កើតកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក

ដោយឡែកកិច្ចសន្យាជួលម៉ាក ពុំត្រូវបានកំណត់របបគតិយុត្តច្បាស់លាស់ម្ចាស់ម៉ាកត្រូវចាត់វិធានការស្របច្បាប់តាមរយៈការតាក់តែងតទប្បញ្ញត្តិជាក់លាក់ និងច្បាស់លាស់ស្របតាមគោលការណ៍ច្បាប់ដែលពាក់ព័ន្ធនិងកិច្ចសន្យាដើម្បីការពារផលប្រយោជន៍របស់ខ្លួនឯង។ នៅក្នុងការតាក់តែងកិច្ចសន្យាជួលម៉ាកនេះម្ចាស់ម៉ាកត្រូវយកចិត្តទុកដាក់លើបទប្បញ្ញត្តិខាងនេះដែលមិនអាចខ្វះបានដោយថៃងលម្អិច និងច្បាស់លាស់នូវចំនុចដូចខាងក្រោម៖[58]

- តម្លៃសមាមាត្រ
- រយៈពេលអនុវត្តនៃកិច្ចសន្យា
- បរិមាណនៃផលិតផល
- រយៈពេលនៃការអនុវត្តសិទ្ធិ
- ទីកន្លែង ឬដែនកំណត់ដែនដីនៃការអនុវត្តសិទ្ធិ
- ការខិតខំប្រឹងប្រែងរបស់ភាគីទទួលអាជ្ញាប័ណ្ណក្នុងការប្រកបអាជីវកម្ម
- ឧបញ្ញាក់អំពីការប្រគល់ត្រលប់មកវិញនូវម៉ាកបន្ទាប់ពីចប់កិច្ចសន្យា
- លក្ខខណ្ឌនៃការដោះស្រាយវិវាទ។ល។

## ២.៤.លក្ខខណ្ឌទម្រង់នៃការបង្កើតកិច្ចសន្យាជួលម៉ាក

យោងតាមគោលការណ៍ទូទៅនៃការបង្កើតកិច្ចសន្យា កិច្ចសន្យាអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។ កិច្ចសន្យាអាជ្ញាប័ណ្ណត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវចុះបញ្ជីជាមួយមន្ត្រីកាន់កាប់បញ្ជីដើម្បីធ្វើកំណត់ត្រា។ ចំពោះការខកខានពុំបានតម្កល់កិច្ចសន្យាអាជ្ញាប័ណ្ណជាមួយមន្ត្រីកាន់កាប់បញ្ជីពុំបណ្តាលឱ្យកិច្ចសន្យានេះបាត់បង់សុពលភាពទេ ប៉ុន្តែវាពុំមានសុពលភាពចំពោះតតិយជនឡើយ។ នៅពេលកិច្ចសន្យានេះ ត្រូវបានចុះបញ្ជី និងការកត់ត្រាដោយមន្ត្រីកាន់កាប់បញ្ជីរួចហើយ មន្ត្រីកាន់កាប់បញ្ជីនឹងធ្វើការបោះផ្សាយជាសាធារណៈនូវការផ្តល់អាជ្ញាប័ណ្ណនេះក្នុងព្រឹត្តិប័ត្ររបស់ក្រសួងពាណិជ្ជកម្ម[59]។

កិច្ចសន្យាអាជ្ញាប័ណ្ណនេះ ត្រូវបានរក្សាជាសម្ងាត់ដោយមន្ត្រីកាន់កាប់បញ្ជី។ ការបោះផ្សាយអាចត្រូវបានអាចត្រូវធ្វើឡើងបានតែចំនុចគោលមួយចំនួន ដែលមិនប៉ះពាល់ដល់ផលប្រយោជន៍របស់គូភាគី។ ក្នុងវិស័យ

---

[57] ដូច2, ទំព័រ១៣២។

[58] ដូច2, ទំព័រ១៣២។

[59] ដូច2, ទំព័រ១៣២-១៣៣។

ពាណិជ្ជកម្ម គូភាគីនៃកិច្ចសន្យាពុំមានបំណងបង្ហាញនូវកិច្ចព្រមព្រៀងឯកជនរបស់ខ្លួនឱ្យសាធារណៈជនបានដឹងលឺឡើយ។ ក្នុងករណីនេះ ទោះបីជាមានកាតព្វកិច្ចរក្សាការសម្ងាត់ដោយមន្ត្រីកាន់កាប់បញ្ជីក៏ដោយគូភាគីអាចធ្វើកិច្ចសន្យាសង្ខេបមួយដើម្បីបញ្ជាក់អំពីអត្ថិភាពនៃការផ្ទេរសិទ្ធិតាមរយៈកិច្ចសន្យាអាជ្ញាប័ណ្ណ[60]។

**កថាខណ្ឌទី៣៖ បញ្ហាប្រឈម**

នៅក្នុងប្រធានបទស្រាវជ្រាវរបស់យើងខ្ញុំនេះដែរ ពួកយើសង្កេតឃើញមានផលវិបាក និងចំនុចខ្វះខាតមួយចំនួនដែលកើតមានឡើងទៅលើប្រធានបទនេះ ដែលជាការរាំងស្ទះដ៏ធំមួយនៅក្នុងការស្រាវជ្រាវមួយនេះដែរ ហើយបញ្ហាទាំងនេះខ្ញុំជឿជាក់ថានិស្សិតមួយចំនួនគឺកំពុងតែជួបប្រទះនឹងបញ្ហានេះដូចគ្នាទៅលើប្រធានបទដែលពាក់ព័ន្ធកម្មសិទ្ធិបញ្ញា។ បញ្ហាទាំងអស់នេះមានដូចជា៖

**ក. ការកង្វះនូវលិខិតបទដ្ឋានគតិយុត្ត៖** ភាពខ្វះខាតនូវឯកសារ ឬ លិខិតបទដ្ឋានគតិយុត្តដែលទាក់ទងទៅនឹងប្រធានបទរបស់យើងខ្ញុំក៏ដូចជាច្បាប់ដែលទាក់ទងនឹងកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកគឺមិនមានច្បាប់ចែងអំពីកិច្ចសន្យាអាជ្ញាប័ណ្ណទេគឺមានតែយកវិធាននៃប្បញ្ញត្តិរួមនៅក្នុងកិច្ចសន្យាទូទៅ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីមកអនុវត្តប៉ុណ្ណោះ ដូចនេះហើយទើបពួកខ្ញុំមានផលវិបាកក្នុងការកំណត់យកបទប្បញ្ញត្តិដែលជាក់លាក់មួយយកមកបញ្ចូលនៅក្នុងប្រធានបទរបស់ពួកយើងនេះណាស់ មិនតែប៉ុណ្ណោះឯកសារបរទេសមួយចំនួន ក៏ពុំមានសរសេរពាក់ព័ន្ធអំពីកិច្ចសន្យាអាជ្ញាម៉ាកនោះទេ គឺភាគច្រើនគឺគេនិយាយអំពីកិច្ចសន្យាខ្ចីម៉ាកទៅវិញ ព្រោះប្រធានបទកិច្ចសន្យាខ្ចីម៉ាកនេះគឺកំពុងមានភាពពេញនិយមជាងគេនៅលើសកលលោកយើងនេះ ជាពិសេសគឺនៅក្នុងវិស័យកម្មសិទ្ធិបញ្ញា។

**ខ. ការកង្វះនូវធនធាន៖** យើងដឹងហើយថាវិស័យកម្មសិទ្ធិបញ្ញានៅក្នុងប្រទេសកម្ពុជា គឺស្ថិតនៅក្នុងកម្រិតមធ្យមនៅឡើយដែលក្នុងនោះ អ្នកច្បាប់ភាគច្រើនគឺមិនសូវមានការចាប់អារម្មណ៍លើវិស័យកម្មសិទ្ធិបញ្ញានៅឡើយទេ ដោយសារតែច្បាប់កម្មសិទ្ធិបញ្ញាគឺមានភាពស្មុគស្មាញខ្លាំង ព្រោះក្នុងការដោះស្រាយក្នុងរឿងក្តីដែលពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា គឺភាគច្រើនគេដោះស្រាយត្រូវមើលទៅលើស្ថានភាពជាក់ស្តែងជៀសជាងច្បាប់ ដោយសារតែមានករណីកើតឡើងគឺមានភាពខុសគ្នាច្រើនមួយវិធានក្នុងការអនុវត្តគឺមានភាពស្រដៀងគ្នាក៏ដោយតែករណីដែលកើតឡើងនោះគឺខុសគ្នាបន្តិចៗ ហើយពិបាកសម្រេចចិត្តក្នុងការយកវិធាននោះមកអនុវត្តណាស់។ ដូចដែលបានរៀបរាប់ខាងនេះ ការកង្វះនូវធនធានគឺមានផលវិបាកខ្លាំងដែលញ៉ាំងឱ្យអ្នកច្បាប់មួយចំនួនគឺមិនបានអនុវត្តតាមកិច្ចសន្យានេះទេ ដោយការចែងតាមច្បាប់ផ្ទុយស្រលះពីការអនុវត្តដែលធ្វើឱ្យពួកគេគិតគឺមានភាពស្មុគស្មាញពេកនិងចង់មានភាពងាយស្រួលក្នុងការអនុវត្តកិច្ចសន្យា

[60] ដូច2, ទំព័រ១៣៣។

ហើយការធ្វើបែបនេះអាចបណ្តាលឱ្យមានវិវាទនឹងគ្នាដែលអាចឈានទៅដល់ការប្តឹងផ្តល់គ្នា ចំពោះរឿងអាជ្ញាប័ណ្ណម៉ាកនេះដោយមូលហេតុគឺមានការធ្វេសប្រហែសខ្លាំងចំពោះការកង្វះនូវធនធាន។

**កថាខណ្ឌទី៤៖ ដំណោះស្រាយ**

កាលណាមានបញ្ហាគឺត្រូវតែមានដំណោះស្រាយ ចំពោះដំណោះស្រាយវិញគឺមិនមានច្រើននោះទេគឺគ្រាន់តែសំនូមពរឱ្យក្រសួងដែលមានសមត្ថកិច្ច ជាពិសេសគឺក្រសួងពាណិជ្ជកម្មគឺជួយបន្ថែមនូវឯកសារមួយចំនួនមានដូចជាបទដ្ឋានគតិយុត្ត និងវិធានមួយចំនួនដែលទាក់ទងនឹងវិស័យកម្មសិទ្ធិបញ្ញា ជាពិសេសគឺកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកដែលបច្ចុប្បន្ន គឺនៅតែអនុវត្តតាមវិធាននៃកិច្ចសន្យាទូទៅនៅឡើយ មួយវិញទៀតក្រសួងគួរតែជំរុញឱ្យមានការសិក្សាឱ្យទូលាយទៅលើវិស័យកម្មសិទ្ធិបញ្ញា នៅក្នុងលើវិស័យអប់រំក្នុងវិស័យច្បាប់ឱ្យមានប្រសិទ្ធិភាព និងសូមឱ្យអ្នកច្បាប់មួយចំនួនត្រូវធ្វើទៅតាមច្បាប់ឱ្យបានម៉ត់ចត់កុំឱ្យមានការធ្វេសប្រហែសជាពិសេទកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកនេះឱ្យសមស្របទៅតាមទម្រង់ និងវិធានទាំងឡាយដែលបានចែងក្នុងគោលបំណងធ្វើឱ្យវិស័យកម្មសិទ្ធិបញ្ញារបស់កម្ពុជាមានប្រសិទ្ធិនិងជាទីទុកចិត្តដល់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសបច្ចុប្បន្ននេះគឺមានការវិនិយោគទៅលើម៉ាកជាច្រើនដែលតម្រូវឱ្យអ្នកច្បាប់ត្រូវយកចិត្តទុកដាក់ និងត្រៀមខ្លួនជានិច្ចដើម្បីធ្វើឱ្យដំណើរការនៃកម្មសិទ្ធិបញ្ញានៅកម្ពុជាដំណើរការទៅដោយរលូន និងមានប្រសិទ្ធិភព។

# ជំពូកទី២

# លក្ខខណ្ឌក្នុងការចុះបញ្ជីអាជ្ញាប័ណ្ណម៉ាក

យើងដឹងហើយថាការចុះបញ្ជីអាជ្ញាប័ណ្ណនៃម៉ាកគឺជាកត្តាសំខាន់ ក្នុងការធ្វើឱ្យកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាកនោះមានសុពលភាព មិនតែប៉ុណ្ណោះថែមទាំងធ្វើឱ្យតតិយមានទំនុកចិត្តទៅលើអាជ្ញាប័ណ្ណរបស់ម្ចាស់កម្មសិទ្ធិករ និងសមស្របទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ ទើបធ្វើឱ្យដំណើរការនៃអាជីវកម្មនោះទទួលនូវភាពល្អប្រសើរ ប្រកបដោយប្រសិទ្ធិភាព ដូចនេះក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកគឺយើងសំគាល់ឃើញថាមានការទិញលក់ និងការជួលម៉ាកទៅតាមប្រភេទនៃកិច្ចសន្យារបស់តតិយជន និងម្ចាស់កម្មសិទ្ធិករ ហើយកិច្ចសន្យាទាំងនេះគឺមានវិធានដូចគ្នាទៅនឹងកិច្ចសន្យាទិញលក់ និងកិច្ចសន្យាជួលក្នុងក្រមរដ្ឋប្បវេណីដែរ ដែលវិធាន និងដំណើរការនីតិវិធីទាំងនោះគឺមានលក្ខណៈខុសគ្នាត្រង់ការទិញលក់កម្មវត្ថុរបស់វា គឺការផ្ទេរសិទ្ធិកម្មសិទ្ធិទៅឱ្យតតិយជន ចំណែកឯតតិយជនគឺមានករណីយកិច្ចបង់ថ្លៃជូនទៅដល់ម្ចាស់កម្មសិទ្ធិករ។ ចំពោះកម្មវត្ថុរបស់កិច្ចសន្យាជួលវិញគឺភតិក:(ម្ចាស់កម្មសិទ្ធិ)អាចប្រគល់សិទ្ធិកាន់កាប់ និងអាស្រ័យផលតែប៉ុណ្ណោះទៅឱ្យភតិបតីតែប៉ុណ្ណោះ ឯភតិបតីគឺមានកាតព្វកិច្ចបង់ថ្លៃជួលទៅឱ្យភតិក:ដោយកំណត់អំឡុងពេលជាក់លាក់ណាមួយបន្ទាប់មកនៅពេលដែលកិច្ចសន្យានោះបានផុតកំណត់នោះភតិបតី គឺត្រូវប្រគល់សិទ្ធិទាំងនោះទៅឱ្យភតិក:វិញតាមការកំណត់នៅក្នុងកិច្ចសន្យា។

ចំពោះកិច្ចសន្យាអជាជ្ញាប័ណ្ណណាមួយដែលអំពីការចុះបញ្ជីម៉ាក ឬពាក្យស្នើសុំទទួលស្គាល់កិច្ចសន្យាអាជ្ញាប័ណ្ណនោះត្រូវចែងអំពីការត្រួតពិនិត្យដោយមានប្រសិទ្ធិភាពពីសំណាកអ្នកប្រគល់អាជ្ញាប័ណ្ណ ចំពោះគុណភាពទំនិញ ឬសេវាកម្មរបស់អ្នកទទួលអាជ្ញាប័ណ្ណដែលម៉ាកនោះបានប្រើប្រាស់។ ប្រសិនបើកិច្ចសន្យាអាជ្ញាប័ណ្ណមិនបានចែងអំពីការត្រួតពិនិត្យគុណភាពនោះ ឬប្រសិនបើការត្រួតពិនិត្យគុណភាពនោះមិនត្រូវបានអនុវត្តដោយមានប្រសិទ្ធិភាពទេ ដូចនេះកិច្ចសន្យាអាជ្ញាប័ណ្ណនោះនឹងត្រូវចាត់ទុកជាមិនបានការ[61]។ ហើយលក្ខខណ្ឌនៃការចុះបញ្ជីកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកមាននីតិវិធីដូចតទៅៈ

## ផ្នែកទី១ៈ លក្ខខណ្ឌនីតិវិធី និងឯកសារតម្រូវសម្រាប់ស្នើសុំការកត់ត្រា

### កថាខណ្ឌទី១ៈ លក្ខខណ្ឌតម្រូវទាក់ទងនឹងអ្នកស្នើសុំការកត់ត្រា

ការស្នើសុំកត់ត្រាត្រូវធ្វើឡើងដោយអ្នកផ្តល់ និង/ឬអ្នកទទួល ឬ ដោយអ្នកតំណាងស្របច្បាប់របស់អ្នកផ្តល់ និង/ឬ អ្នកទទួល[62]។

---

[61] ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៦ ធ្នូ ២០០១, មាត្រា១៩ (ពីពេលនេះតទៅហៅថា ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ឆ្នាំ២០០១)។

[62] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ៥។

### ១. លក្ខខណ្ឌតម្រូវទាក់ទងនឹងកិច្ចសន្យា

កិច្ចសន្យាដែលជាកម្មវត្ថុនៃការស្នើសុំកត់ត្រាត្រូវបញ្ជាក់ខ្លឹមសារសំខាន់ៗ ដូចខាងក្រោម៖

១-អត្តសញ្ញាណរបស់អ្នកផ្តល់ និងអ្នកទទួលរួមមាន៖

- ឈ្មោះ សញ្ជាតិ និងអាសយដ្ឋានអចុន្ត្រៃយ៍ ក្នុងករណីអ្នកផ្តល់ និងអ្នកទទួលជារូបវន្តបុគ្គល
- នាមករណ៍សញ្ជាតិនិងអាសយដ្ឋានទីស្នាក់ការដែលបានចុះបញ្ជីក្នុងករណីអ្នកផ្តល់ និងអ្នកទទួលជានីតិបុគ្គល។

២-ព័ត៌មានលម្អិតអំពីម៉ាក រួមមាន ម៉ាក លេខចុះបញ្ជី ឬលេខដាក់ពាក្យចុះបញ្ជីម៉ាក ជំពូកទំនិញ ឬសេវា និងយថាប្រភេទនៃទំនិញ និង/ឬ សេវាដែលជាកម្មវត្ថុនៃការកត់ត្រា។

៣-ប្រភេទនៃអាជ្ញាប័ណ្ណ ឬសិទ្ធិប្រកបអាជីវកម្មដែលបានផ្តល់តាមរយៈកិច្ចសន្យា៖ ផ្តាច់មុខ ទោល ឬបន្ត។

៤-រយៈពេលនៃការផ្តល់ត្រូវកំណត់ឱ្យបានជាក់លាក់ក្នុងកិច្ចសន្យា ឬអាចកំណត់បានដោយយោងតាមលក្ខខណ្ឌ និងបញ្ញត្តិដែលមានចែងក្នុងកិច្ចសន្យាពាក់ព័ន្ធផ្សេងទៀត។

៥-លក្ខខណ្ឌនៃការត្រួតពិនិត្យលើប្រសិទ្ធភាព និងគុណភាពទំនិញឬសេវាដែលបានព្រមព្រៀងគ្នារវាងអ្នកផ្តល់ និងអ្នកទទួល។

៦-ហត្ថលេខារបស់ភាគី និងការបញ្ជាក់ពីភាពត្រឹមត្រូវដោយសារការីឬអាជ្ញាធរមានសមត្ថកិច្ច[63]។

#### ១.១. ពាក្យស្នើសុំកត់ត្រា

អ្នកស្នើសុំការកត់ត្រាត្រូវបំពេញតាមគំរូពាក្យស្នើសុំកត់ត្រាក្រសួងពាណិជ្ជកម្ម ហើយពាក្យស្នើសុំកត់ត្រាត្រូវចុះហត្ថលេខាដោយអ្នកស្នើសុំការកត់ត្រា ឬដោយអ្នកតំណាងស្របច្បាប់របស់អ្នកស្នោះសុំនោះ។ ក្នុងករណីអ្នកស្នើសុំកត់ត្រាជានីតិបុគ្គល ពាក្យស្នើសុំត្រូវចុះហត្ថលេខា និងមានប្រថាប់ត្រា។

ពាក្យស្នើសុំមួយគឺអាចធ្វើឡើងសម្រាប់ការស្នើសុំកត់ត្រាកិច្ចសន្យាមួយលើម៉ាកមួយ ចំពោះទំនិញ ឬសេវាក្នុងមួយ ឬ ច្រើនជំពូក[64]។

#### ១.២. ការដាក់ពាក្យស្នើសុំកត់ត្រា

ការដាក់ពាក្យស្នើសុំកត់ត្រាកិច្ចសន្យា ត្រូវធ្វើឡើងក្នុងពេលណាមួយនៃអំឡុងពេល ៦(ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃការចុះកិច្ចសន្យានោះ។ ហើយពាក្យស្នើសុំកត់ត្រាដែលបានបំពេញ

[63] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ៦។

[64] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ៧។

នោះត្រូវដាក់នៅនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មដើម្បីត្រួតពិនិត្យ និងសម្រេច។ ចំពោះការដាក់ពាក្យស្នើសុំកត់ត្រា ត្រូវមានភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម៖

ក-ច្បាប់ដើម ឬ ច្បាប់ចម្លងនៃកិច្ចសន្យាដែលមានបញ្ជាក់ភាពត្រឹមត្រូវ ដោយសារការី ឬ អាជ្ញាធរមានសមត្ថកិច្ចស្របតាមច្បាប់ជាធរមាន។

ខ- ក្នុងករណីដែលកិច្ចសន្យាទាំងមូលមិនអាចផ្តល់ជូនមន្ត្រីទទួលមន្ទុកការកត់ត្រា អ្នកស្នើសុំត្រូវផ្តល់សម្រង់នៃកិច្ចសន្យាដែលសម្រង់នោះត្រូវមានការបញ្ជាក់ខ្លឹមសារសំខាន់ៗ និងត្រូវមានការបញ្ជាក់ភាពត្រឹមត្រូវដោយសារការី ឬអាជ្ញាធរមានសមត្ថកិច្ចស្របតាមច្បាប់ជាធរមាន។

គ- ក្នុងករណីកិច្ចសន្យាឬសម្រង់នៃកិច្ចសន្យា ជាភាសាបរទេសក្រៅពីភាសាអង់គ្លេស ត្រូវបកប្រែជាភាសាខ្មែរ និងត្រូវមានការបញ្ជាក់ពីភាពត្រឹមត្រូវតាមច្បាប់ដើមនៃការបកប្រែនោះ។

ឃ- លិខិតប្រគល់សិទ្ធិ និងលិខិតប្រគល់សិទ្ធិបន្តច្បាប់ដើម ប្រសិនបើការដាក់ពាក្យស្នើសុំធ្វើឡើងតាមរយៈភ្នាក់ងារតំណាងស្របច្បាប់។

ង- ច្បាប់ចម្លងនៃវិញ្ញាបនបត្រចុះបញ្ជីម៉ាកដើម ឬវិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី ឬលិខិតទទួលស្គាល់ការដាក់ពាក្យចុះបញ្ជីម៉ាកក្នុងករណីម៉ាក ដែលបានដាក់ពាក្យសុំចុះបញ្ជីរួចរាល់ ប៉ុន្តែមិនទាន់ទទួលបានការចុះបញ្ជីនៅឡើយ។

ច- ឯកសារតម្រូវរបស់អ្នកផ្តល់៖

១-ក្នុងករណីជានីតិបុគ្គល៖ ច្បាប់ចម្លងឯកសារពាក់ព័ន្ធនឹងការចុះបញ្ជី ពាណិជ្ជកម្ម។

ក. សញ្ជាតិខ្មែរ៖ ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណ ដោយមានហត្ថលេខា ឬ ស្នាមមេដៃរបស់សមីខ្លួន។

ខ. សញ្ជាតិបរទេស និងមានទីតាំងប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា៖ ច្បាប់ចម្លងលិខិតឆ្លងដែន ទិដ្ឋាការដែលមានសុពលភាព និងឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីប្រកបអាជីវកម្ម។

២-ក្នុងករណីជានីតិបុគ្គល៖ ច្បាប់ចម្លងឯកសារពាក់ព័ន្ធនឹងការចុះបញ្ជី ពាណិជ្ជកម្ម។

ឆ-ឯកសារតម្រូវរបស់អ្នកទទួល៖

១. ក្នុងករណីជារូបវន្តបុគ្គល៖

ក. សញ្ជាតិខ្មែរ៖ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណដោយមានហត្ថលេខា ឬ ស្នាមមេដៃរបស់សាមីខ្លួន។

ខ. សញ្ជាតិបរទេស និងមានទីតាំងប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា៖ ច្បាប់

ចម្លងលិខិតឆ្លងដែន ទិដ្ឋាការដែលមានសុពលភាពនិង ឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីប្រកបអាជីវកម្ម។

២. ក្នុងករណីជានីតិបុគ្គលៈ ត្រូវយកច្បាប់ចម្លងឯកសារពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម។ចំពោះអ្នកផ្តល់និងអ្នកទទួលជារូបវន្តបុគ្គល និងនីតិបុគ្គលបរទេសដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍ ឬ ទីតាំងប្រកបអាជីវកម្មនៅក្រៅព្រះរាជាណាចក្រកម្ពុជាមិនតម្រូវឱ្យផ្តល់ឯកសារដូចមានចែងក្នុងចំណុច(ច) និង(ឆ)ឡើយ ហើយបង្កាន់ដៃបង់កម្រៃសេវាសាធារណៈ[65]។

**កថាខណ្ឌទី២៖ នីតិវិធីនៃការត្រួតពិនិត្យពាក្យស្នើសុំកត់ត្រា**

ការកត់ត្រាកិច្ចសន្យាអាចធ្វើទៅបានលុះត្រាតែអ្នកដាក់ពាក្យស្នើសុំបានបំពេញគ្រប់លក្ខខណ្ឌតម្រូវសម្រាប់ស្នើសុំការកត់ត្រានេក្នុងករណីម៉ាកដែលបានដាក់ពាក្យស្នើសុំចុះបញ្ជី នៅក្នុងព្រះរាជណាចក្រកម្ពុជា ការស្នើសុំកត់ត្រាកិច្ចសន្យានឹងត្រូវយកមកត្រួតពិនិត្យ នៅពេលដែលម៉ាកនោះទទួលបានការចុះបញ្ជីរួចក្រោយពេលទទួលពាក្យស្នើសុំកត់ត្រាមន្ត្រីទទួលបន្ទុកកត់ត្រា ត្រូវពិនិត្យមើលពាក្យស្នើសុំនោះ ឱ្យបានត្រឹមត្រូវតាមគ្រប់លក្ខខណ្ឌតម្រូវសម្រាប់ការស្នើសុំការកត់ត្រានេះ។ ក្នុងករណីដែលមន្ត្រីទទួលបន្ទុកកត់ត្រារកឃើញថា លក្ខខណ្ឌតម្រូវសម្រាប់ការស្នើសុំកត់ត្រាណាមួយមិនត្រូវបានបំពេញ ឬ ពាក្យស្នើសុំកត់ត្រាឬឯកសារដែលប្រើប្រាស់ភ្ជាប់មកជាមួយពាក្យស្នើសុំមានលក្ខណៈមិនត្រឹមត្រូវ ឬ មិនគ្រប់គ្រាន់មន្ត្រីទទួលបន្ទុកកត់ត្រាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធបឋម ចំពោះការកត់ត្រានោះទៅអ្នកដាក់ពាក្យស្នើសុំការកត់ត្រាក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីបានទទួលពាក្យស្នើសុំកត់ត្រា។ ការជូនដំណឹងនេះត្រូវបញ្ជាក់ពីព័ត៌មានពាក់ព័ន្ធនឹងមូលហេតុនៃការបដិសេធបឋមនោះដោយផ្តល់រយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងដើម្បីតម្រូវឱ្យអ្នកដាក់ពាក្យ ស្នើសុំការកត់ត្រាបំពេញលក្ខខណ្ឌ និងឆ្លើយតបជាលាយលក្ខណ៍អក្សរទៅមន្ត្រីទទួលបន្ទុកកត់ត្រា។ អ្នកស្នើសុំការកត់ត្រាអាចស្នើសុំពន្យាពេលមិនឱ្យលើស៦០(ហុកសិប)ថ្ងៃ បន្តទៀតសម្រាប់ការឆ្លើយតបជាលាយលក្ខណ៍អក្សរក្នុងករណីមានហេតុផលសមស្រប[66]។

**២. ការបដិសេធពាក្យស្នើសុំកត់ត្រា**

ប្រសិនបើអ្នកស្នើសុំការកត់ត្រាមិនធ្វើការឆ្លើយតបក្នុងរយៈពេលកំណត់ ដូចមានចែងក្នុងចំណុច៤នៃប្រការ៩ខាងលើ ពាក្យស្នើសុំកត់ត្រានោះត្រូវបានចាត់ទុកថាបានបោះបង់ចោល។ ដូនេះមន្ត្រីទទួលបន្ទុកកត់ត្រាគឺត្រូវបដិសេធការស្នើសុំកត់ត្រាក្នុងករណីរកឃើញថាកិច្ចសន្យាៈ

ក. មានលក្ខណៈមិនត្រឹមត្រូវតាមទម្រង់ច្បាប់ ឬ ក្លែងបន្លំ ឬ

[65] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ៨។

[66] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ៩។

ខ. បណ្តាលឱ្យមានការភ័ន្តច្រឡំដល់សាធារណជន ជាពិសេសចំពោះ៖ ប្រភេទ ប្រភពដើម ដំណើរការផលិតកម្ម ចរិតលក្ខណៈ ភាពសមស្របនៃទំនិញ ឬ សេវាដែលម៉ាកនោះបម្រុងប្រើប្រាស់ ឬ កំពុងប្រើប្រាស់ ឬ

គ. មានលក្ខណៈផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ប្រពៃណីល្អរបស់ជាតិ ឬ គោលនយោបាយរបស់រាជរដ្ឋាភិបាល។ ដូចមានចែងក្នុងកថាខណ្ឌទី២នៃប្រការនេះមន្ត្រីទទួលបន្ទុកកត់ត្រាត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធចុងក្រោយ នៃការស្នើសុំកត់ត្រាកិច្ចសន្យាទៅអ្នកដាក់ពាក្យស្នើសុំដោយបញ្ជាក់ពីព័ត៌មានពាក់ព័ន្ធនឹងមូលហេតុនៃការបដិសេធនោះ។

សេចក្តីសម្រេចនេះគឺជាកម្មវត្ថុនៃបណ្តឹងតវ៉ាទៅ ក្រុមប្រឹក្សាដោះស្រាយបណ្តឹងតវ៉ានៃក្រសួងពាណិជ្ជកម្ម ឬ ទៅតុលាការមានសមត្ថកិច្ចក្នុងរយៈពេល៩០(កៅសិប)ថ្ងៃគិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច[67]។

### ២.១. ការយល់ព្រមចំពោះការស្នើសុំកត់ត្រា និងការបោះពុម្ពផ្សាយ

ប្រសិនបើពិនិត្យឃើញថាពាក្យស្នើសុំកត់ត្រាកិច្ចសន្យា និងឯកសារភ្ជាប់មកជាមួយពាក្យស្នើសុំនោះបានបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ការកត់ត្រា មន្ត្រីទទួលបន្ទុកកត់ត្រាត្រូវធ្វើការកត់ត្រាកិច្ចសន្យានោះ។

បន្ទាប់ពីបានកត់ត្រាកិច្ចសន្យារួចហើយ ត្រូវធ្វើការបោះពុម្ពផ្សាយភ្លាមនៅក្នុងព្រឹត្តិការរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានូវសម្រង់ព័ត៌មានជាអាទិ៍ដូចខាងក្រោម៖

ក-ឈ្មោះ និងអាសយដ្ឋាន របស់អ្នកផ្តល់ និងអ្នកទទួល។

ខ-គំរូម៉ាក និងលេខចុះបញ្ជីម៉ាក ដែលជាកម្មវត្ថុនៃកិច្ចសន្យា។

គ-ជំពូក និងយថាប្រភេទនៃទំនិញ ឬសេវា ដែលជាកម្មវត្ថុនៃកិច្ចសន្យា។

ឃ-ប្រភេទនៃអាជ្ញាប័ណ្ណ ឬសិទ្ធិប្រកបអាជីវកម្ម។

ង-កាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំកត់ត្រាកាលបរិច្ឆេទនៃការកត់ត្រានិងរយៈពេលសុពលភាពនៃការកត់ត្រានោះ។

ច-ដែនដីនៃការផ្តល់អាជ្ញាប័ណ្ណ ឬការផ្តល់សិទ្ធិប្រកបអាជីវកម្ម។

ឆ-ឈ្មោះ និងអាសយដ្ឋាន របស់ភ្នាក់ងារតំណាងរបស់អ្នកស្នើសុំកត់ត្រា (ប្រសិនបមាន)[68]។

### ២.២. ការស្នើសុំកែតម្រូវពាក្យស្នើសុំកត់ត្រា

នៅមុនមានការកត់ត្រាកិច្ចសន្យាអ្នកស្នើសុំកត់ត្រា ឬអ្នកតំណាងស្របច្បាប់អាចធ្វើការស្នើសុំជា

[67] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ១០។

[68] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ១១។

លាយលក្ខណ៍អក្សរទៅកាន់មន្ត្រីទទួលបន្ទុកកត់ត្រា ដើម្បីកែតម្រូវផ្នែកណាមួយនៃពាក្យស្នើសុំកត់ត្រា ជាពិសេសសេចក្តីលម្អិតអំពីម៉ាកនិងមុខទំនិញឬសេវាដែលជាកម្មវត្ថុនៃកិច្ចសន្យាឬលក្ខខណ្ឌ ឬ ការកម្រិតកំណត់នៃការផ្តល់អាជ្ញាប័ណ្ណឬការផ្តល់សិទ្ធិប្រកបអាជីវកម្មដែលបានព្រមព្រៀងក្នុងកិច្ចសន្យា។ ចំពោះការស្នើសុំកែតម្រូវពាក្យស្នើសុំកត់ត្រាកិច្ចសន្យា គឺត្រូវបំពេញតាមគំរូពាក្យស្នើសុំកែតម្រូវ។ ពាក្យស្នើសុំនេះត្រូវចុះហត្ថលេខា ដោយអ្នកស្នើសុំឬដោយអ្នកតំណាងស្របច្បាប់របស់អ្នកស្នើសុំនោះ។ ហើយក្នុងករណីអ្នកស្នើសុំកែតម្រូវពាក្យស្នើសុំកត់ត្រាជានីតិបុគ្គលពាក្យស្នើសុំត្រូវចុះហត្ថលេខា និងប្រថាប់ត្រា[69]។

### ២.៣. ការដកពាក្យស្នើសុំកត់ត្រា

នៅមុនមានការកត់ត្រាកិច្ចសន្យា ការដកពាក្យស្នើសុំកត់ត្រាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និង ត្រូវចុះហត្ថលេខាដោយអ្នកដាក់ពាក្យស្នើសុំកត់ត្រា ឬអ្នកតំណាងស្របច្បាប់របស់អ្នកស្នើសុំនោះ[70]។

### កថាខណ្ឌទី៣៖ តម្លៃនៃការចុះបញ្ជីអាជ្ញាប័ណ្ណម៉ាក

បន្ទាប់ពីពីការសុំកត់ត្រាមកគឺត្រូវមានការបង់ថ្លៃការសុំកត់ត្រាអាជ្ញាប័ណ្ណនេះ ដែលការបង់ថ្លៃសេវានេះគឺត្រូវយកទៅបង់នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលការកត់ត្រានេះ គឺមានរយៈពេល៦០ថ្ងៃដែលមានទឹកប្រាក់ចំនួន ៤០០ ០០០រៀល ស្របតាមកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក[71]។

## ផ្នែកទី២៖ អានុភាពនៃការកត់ត្រា

### កថាខណ្ឌទី១៖ សុពលភាពសិទ្ធិនិងកាតព្វកិច្ច

### ១. សុពលភាពនៃការកត់ត្រា

កិច្ចសន្យាណាមួយដែលមិនបានកត់ត្រានឹងមិនមានអានុភាពចំពោះភាគីទីបីឡើយ។ ការកត់ត្រាកិច្ចសន្យាត្រូវមានសុពលភាព៥(ប្រាំ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការកត់ត្រាឬមានសុពលភាពតិចជាង៥(ប្រាំ)ឆ្នាំដោយយោងតាមសុពលភាពនៃកិច្ចសន្យា និង ការចុះបញ្ជីម៉ាក។

### ១.២. ការបន្តសុពលភាពនៃការកត់ត្រា

ការបន្តសុពលភាពនៃការកត់ត្រាអាចធ្វើឡើងសម្រាប់រយៈពេល៥(ប្រាំ)ឆ្នាំម្តង ដោយគិតចាប់ពីកាលបរិច្ឆេទផុតសុពលភាពនៃការកត់ត្រា ចំពោះសុពលភាពនៃការបន្តការកត់ត្រាគឺ ត្រូវយោងតាមសុពលភាពនៃកិច្ចសន្យា និងការចុះបញ្ជីម៉ាក។

[69] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ១៤។

[70] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ១៥។

[71] ប្រកាសរួមស្តីពីការផ្តល់សេវាសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម, លេខ១២១៧, ២៧ វិច្ឆិកា ២០១៧។

ចំពោះបុគ្គលដែលមានគោលបំណងបន្តសុពលភាពនៃការកត់ត្រានៃកិច្ចសន្យានេះ ត្រូវដាក់ពាក្យស្នើសុំក្នុងអំឡុងពេល៦(ប្រាំមួយ)ខែមុនកាលបរិច្ឆេទផុតសុពលភាពនៃការកត់ត្រា ហើយត្រូវបំពេញតាមនីតិវិធី និងលក្ខខណ្ឌដូចខាងក្រោម៖

ក. ត្រូវបំពេញលក្ខខណ្ឌនិងនីតិវិធីដូចមានចែងក្នុងជំពូក២នៃប្រកាសនេះ។

ខ. អ្នកដាក់ពាក្យស្នើសុំត្រូវបង់កម្រៃសេវាសាធារណៈដូចបានកំណត់ក្នុងប្រកាសជាធរមាន។ ច្បាប់ចម្លងនៃកិច្ចសន្យានិងឯកសារពាក់ព័ន្ធដែលបានតម្កល់រួចហើយនៅមានសុពលភាពនៅឡើយ។

គ. អ្នកស្នើសុំអាចដាក់ឯកសារពាក់ព័ន្ធបន្ថែមដើម្បីបន្តសុពលភាពនៃការកត់ត្រាតាមការតម្រូវរបស់មន្ត្រីទទួលបន្ទុកកត់ត្រា[72]។

### ១.៣. ការបាត់បង់សុពលភាពជាស្វ័យប្រវត្តិនិងការលុបចោលការកត់ត្រា

សុពលភាពនៃការកត់ត្រាកិច្ចសន្យាត្រូវបាត់បង់ជាស្វ័យប្រវត្តិប្រសិនបើ៖

ក. សិទ្ធិដែលបានផ្តល់បានដកហូតមកវិញឬលុបដោយហេតុផលណាមួយ ឬ ការបញ្ចប់កិច្ចសន្យាមុនកាលកំណត់ដោយគោងតាមការកំណត់ជាមុនឬការព្រមព្រៀងរបស់គូភាគី ឬ

ខ. សុពលភាពនៃការចុះបញ្ជីម៉ាកបានបាត់បង់ដោយប្រការណាមួយឬ

គ. ម៉ាកដែលបានចុះបញ្ជីត្រូវបានប្តូរម្ចាស់កម្មសិទ្ធិ។

រាល់លក្ខខណ្ឌគឺតម្រូវឱ្យជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់នាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម។ តាមការស្នើសុំពីភាគីដែលពាក់ព័ន្ធក្រសួងពាណិជ្ជកម្មត្រូវចេញសេចក្តីសម្រេចលុបចោលការកត់ត្រាកិច្ចសន្យា ដោយឈរលើមូលហេតុក្នុងចំណុចមួយ ឬច្រើនខាងលើដោយបង់កម្រៃសេវាសាធារណៈទៅតាមការកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ការបាត់បង់សុពលភាពនិងការលុបចោលការកត់ត្រានេះត្រូវមានអនុភាពចាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីសម្រេច[73]។

### ១.៤. មោឃភាពនៃការកត់ត្រា

ក្រសួងពាណិជ្ជកម្មត្រូវធ្វើមោឃភាពការកត់ត្រាកិច្ចសន្យាប្រសិនបើរកឃើញថា៖

- លក្ខខណ្ឌតម្រូវណាមួយដូចមានចែងក្នុងប្រការ៨សម្រាប់ស្នើសុំការកត់ត្រាមិនបានបំពេញ ឬ
- កិច្ចសន្យាដែលមិនបានចែងអំពីការត្រួតពិនិត្យ ដោយប្រសិទ្ធភាពពីសំណាក់អ្នកផ្តល់ចំពោះគុណភាពទំនិញ ឬ សេវារបស់អ្នកទទួលដែលម៉ាកនោះត្រូវប្រើប្រាស់ ឬ

---

[72] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ១៦។

[73] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ១៧។

- ការត្រួតពិនិត្យគុណភាពទំនិញ ឬ សេវារបស់អ្នកទទួលដែលម៉ាកត្រូវប្រើប្រាស់មិនត្រូវបានអនុវត្តដោយប្រសិទ្ធភាព ឬ
- កិច្ចសន្យាមានលក្ខណៈណាមួយដូចដែលបានរៀបរាប់ក្នុងប្រការ១០(២)ខាងលើ ឬ
- កិច្ចសន្យាមានភាពមិនប្រក្រតីដោយប្រការណាមួយ។

បុគ្គលដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងការកត់ត្រា អាចធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មឱ្យធ្វើមោឃភាពការកត់ត្រាកិច្ចសន្យាបាន ប្រសិនបើមានភស្តុតាងបង្ហាញអំពីមូលហេតុណាមួយខាងលើ។ ចំពោះការធ្វើមោឃភាពការកត់ត្រាកិច្ចសន្យាត្រូវមានអនុភាពអនុវត្តចាប់ពីកាលបរិច្ឆេទនៃការកត់ត្រា[74]។

**កថាខណ្ឌទី២៖ ការផ្លាស់ប្តូរផ្សេងៗទាក់ទងនឹងការកត់ត្រា**

មន្ត្រីទទួលបន្ទុកកត់ត្រាត្រូវធ្វើការកត់ត្រា និងបោះពុម្ពផ្សាយជាសាធារណៈក្នុងព្រឹត្តិបត្រផ្លូវការរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញានូវរាល់ការផ្លាស់ប្តូរសំខាន់ៗទាក់ទងនឹង ការកត់ត្រាកិច្ចសន្យាដូចខាងក្រោម៖

ក-ការផ្លាស់ប្តូរទៅលើខ្លឹមសារសំខាន់ៗនៃកិច្ចសន្យាដែលត្រូវបានកត់ត្រា ជាពិសេសការផ្លាស់ប្តូរដែលទាក់ទងនឹងវិសាលភាពនៃការផ្តល់រយៈពេលនៃកិច្ចសន្យាម៉ាកមុខទំនិញ ឬ សេវាដែលជាកម្មវត្ថុនៃកិច្ចសន្យានោះ។

ខ-ការផ្លាស់ប្តូរទាក់ទងនឹងភាគីនៃកិច្ចសន្យាដែលត្រូវបានកត់ត្រា។ អ្នកដាក់ពាក្យស្នើសុំឬអ្នកតំណាងស្របច្បាប់របស់អ្នកដាក់ពាក្យស្នើសុំ ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរមកនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្មដើម្បីស្នោះសុំកត់ត្រាការផ្លាស់ប្តូរផ្សេងៗ[75]។

**២. ការកែតម្រូវកំហុសបច្ចេកទេស**

នៅក្នុងលក្ខខណ្ឌនៃការការកែតម្រូវកំហុសបច្ចេកទេស មន្ត្រីទទួលបន្ទុកកត់ត្រាអាចធ្វើការកែប្រែចំណុចណាមួយនៃការកត់ត្រាកិច្ចសន្យាដោយឆន្ទានុសិទ្ធិបានប្រសិនបើរកឃើញថាការកត់ត្រានោះ ត្រូវបានធ្វើឡើងដោយមានកំហុសបច្ចេកទេសរបស់មន្ត្រីទទួលបន្ទុកការកត់ត្រា។

តាមការស្នើសុំមន្ត្រីទទួលបន្ទុកការកត់ត្រាអាចកែតម្រូវកំហុសបន្តិចបន្តួច ប្រសិនបើការស្នើសុំកែតម្រូវកំហុសនោះមិនធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់គូភាគី ហើយរាល់ការកែតម្រូវណាមួយទៅលើកំហុសបច្ចេកទេសទាក់ទងនឹងការកត់ត្រាកិច្ចសន្យា ដោយមន្ត្រីទទួលបន្ទុកការកត់ត្រាត្រូវធ្វើការជូនដំណឹងទៅអ្នកស្នើ

[74] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ១៨។
[75] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ១៩។

សុំការកត់ត្រាឬអ្នកតំណាងស្របច្បាប់របស់អ្នកស្នើសុំការកត់ត្រានោះ[76]។

### ២.១. សិទ្ធិទទួលបានពីការកត់ត្រា

នៅពេលដែលកិច្ចសន្យាកត់ត្រារួចអ្នកទទួលមានសិទ្ធិអនុវត្តសិទ្ធិលើម៉ាក ដែលទទួលបានពីកិច្ចសន្យាក្នុងកម្រិតដែលអនុញ្ញាតដោយច្បាប់និងបទប្បញ្ញត្តិជាធរមានអ្នកទទួលមានសិទ្ធិៈ

ក-ដាក់ពាក្យបណ្ដឹងជាលាយលក្ខណ៍អក្សរទៅកាន់តុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចដើម្បីទប់ស្កាត់ការរំលោភការដែលនឹងមានការរំលោភ ឬទង្វើដែលមិនស្របច្បាប់ដូចមានចែងក្នុងច្បាប់ស្ដីពីម៉ាកពាណិជ្ជនាមនិងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ និងបទប្បញ្ញត្តិជាធរមានព្រមទាំងស្នើឱ្យតុលាការសម្រេចលើសំណងការខូចខាតនិងផ្ដល់ដំណោះស្រាយផ្សេងៗដែលមានចែងក្នុងច្បាប់ជាធរមាន។

ខ-ក្នុងករណីដែលអ្នកទទួលបានស្នើសុំទៅអ្នកផ្ដល់ឱ្យប្ដឹងទៅតុលាការ ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ប្រឆាំងនឹងការរំលោភលើម៉ាកឬអំពោះនៃការប្រកួតប្រជែងមិនស្មោះត្រង់ដែលពាក់ព័ន្ធនឹងម៉ាក ប៉ុន្តែអ្នកផ្ដល់បានបដិសេធ ឬខកខានមិនបានដាក់ពាក្យបណ្ដឹងទេនោះអ្នកទទួលអាចប្ដឹងទៅតុលាការមានសមត្ថកិច្ចដោយផ្ទាល់តាមនីតិវិធីច្បាប់ជាធរមាន។

គ-ក្នុងករណីដែលអ្នកទទួលសំណូមពរទៅអ្នកផ្ដល់ឱ្យស្នើសុំអាជ្ញាធរមានសមត្ថកិច្ចចាប់វិធានការ តាមច្បាប់ដើម្បីប្រឆាំងនឹងអំពើរំលោភលើម៉ាក ប៉ុន្តែអ្នកផ្ដល់បានបដិសេធ ឬខកខានមិនបានចាត់វិធានការទេនោះអ្នកទទួលអាចស្នើសុំអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការដោយផ្ទាល់បាន ក្នុងកម្រិតសិទ្ធិលើម៉ាកដែលខ្លួនបានទទួលតាមរយៈកិច្ចសន្យា។

ឃ-ចូលរួមអន្តរាគមន៍ក្នុងបណ្ដឹងប្រឆាំងនឹងការរំលោភលើម៉ាក ឬការប្រកួតប្រជែងមិនស្មោះត្រង់ពាក់ព័ន្ធនឹងម៉ាកដែលផ្ដួចផ្ដើមដោយម្ចាស់ម៉ាក ឬអ្នកផ្ដល់ដើម្បីទាមទារការជួសជុលព្យាសនកម្មដែលខ្លួនបានទទួលរងដោយផ្ទាល់ពីការរំលោភលើម៉ាកឬការប្រកួតប្រជែងមិនស្មោះត្រង់នោះ[77]។

### ២.២. ភាតព្វកិច្ចកើតចេញពីការកត់ត្រា

តាមការចាំបាច់អ្នកស្នើសុំការកត់ត្រាអាចចុះផ្សាយលិខិតកត់ត្រាកិច្ចសន្យា ក្នុងបណ្ដាញសារព័ត៌មានក្នុងប្រទេសកម្ពុជាបន្ទាប់ពីទទួលបាននូវការកត់ត្រា។ អ្នកស្នើសុំការកត់ត្រាអាចបញ្ជូនច្បាប់ចម្លងលិខិតកត់ត្រាកិច្ចសន្យាទៅកាន់ភាគីពាក់ព័ន្ធដើម្បីបានជ្រាបជាព័ត៌មាន និងអនុវត្តតាមលិខិតកត់ត្រាកិច្ចសន្យាត្រូវចុះផ្សាយក្នុងព្រឹត្តិបត្រផ្លូវការរបស់នាយកដ្ឋានកម្មសិទ្ធិបញ្ញា ចំពោះភាគីពាក់ព័ន្ធទាំងឡាយដែលបាននិងកំពុងធ្វើសកម្មភាពរំលោភទៅលើសិទ្ធិរបស់អ្នកផ្ដល់ឬអ្នកទទួល ឬធ្វើសកម្មភាពដែលមានលក្ខណៈជាការប្រកួតប្រជែង

[76] ប្រកាសស្ដីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្ដល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ១៩។

[77] ប្រកាសស្ដីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្ដល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ២០។

មិនស្មោះត្រង់ចំពោះការប្រើប្រាស់ម៉ាក ដែលជាកម្មវត្ថុនៃកិច្ចសន្យាដែលបានកត់ត្រានៅនាយកដ្ឋានកម្មសិទ្ធិបញ្ញាត្រូវបញ្ឈប់ជាបន្ទាន់នូវសកម្មភាពទាំងនោះ គិតចាប់ពីកាលបរិច្ឆេទនៃការកត់ត្រា។ អ្នកផ្តល់ត្រូវចាត់វិធានការចាំបាច់ដូចមានចែងក្នុងកិច្ចសន្យា ដើម្បីត្រួតពិនិត្យដោយប្រសិទ្ធភាពចំពោះគុណភាពទំនិញឬសេវារបស់អ្នកទទួលដែលប្រើប្រាស់ម៉ាកនោះ។ ការត្រួតពិនិត្យគុណភាពនោះត្រូវធ្វើឡើងជាប្រចាំតាមការកំណត់ក្នុងកិច្ចសន្យាឬដោយមិនបានជូនដំណឹងជាមុនអ្នកទទួលត្រូវសហការ និងជួយសម្រួលដល់ការត្រួតពិនិត្យប្រកបដោយប្រសិទ្ធិភាពពីសំណាក់អ្នកផ្តល់ ចំពោះគុណភាពទំនិញឬសេវារបស់ខ្លួនដែលប្រើប្រាស់ម៉ាកដែលជាកម្មវត្ថុនៃកិច្ចសន្យា[78]។

[78] ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម២០២០, ប្រការ២១។

# ជំពូកទី៣
# យន្តការនៃការអនុវត្តកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាក

ដោយសារតែនៅប្រទេសកម្ពុជាមិនទាន់មានច្បាប់ឬបទប្បញ្ញត្តិ ពិសេសដែលកំណត់អំពីរបបគតិយុត្ត គ្រប់គ្រងលើកិច្ចសន្យាអាជ្ញាប័ណ្ណកិច្ចសន្យាអាជ្ញាប័ណ្ណត្រូវបានគ្រប់គ្រងនិងអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិនានាដូចជាច្បាប់រដ្ឋប្បវេណីឬច្បាប់កិច្ចសន្យា។ល។ ការអនុវត្តកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាកអាចប្រៀបធៀបជាមួយកិច្ចសន្យាទិញលក់ម៉ាកនិងកិច្ចសន្យាជួលម៉ាកដែលមានច្បាប់ ឬបទប្បញ្ញត្តិចែងអំពីយន្តការនៃការអនុវត្តកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកនេះ។

## ផ្នែកទី១៖ ការប្រៀបធៀបកិច្ចសន្យាទិញលក់ ម៉ាក និង កិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាក

កិច្ចសន្យាទិញលក់ គឺជាកិច្ចសន្យាមួយដែលភាគីម្ខាងហៅថា "អ្នកលក់" មានករណីយកិច្ចត្រូវផ្ទេរកម្មសិទ្ធិលើវត្ថុណាមួយទៅឱ្យភាគីម្ខាងទៀតហៅថា«អ្នកទិញ»ហើយអ្នកទិញនេះមានករណីយកិច្ច ទូទាត់លុយជាថ្លៃវត្ថុនោះទៅឱ្យអ្នកលក់(មាត្រា៥១៥)។

ក្នុងកិច្ចសន្យាទិញលក់ម៉ាកភាគីម្ខាងលក់កម្មសិទ្ធិ ទាំងឡាយលើម៉ាកណាមួយទៅឱ្យភាគីម្ខាងទៀត។ ប៉ុន្តែក្នុងករណីអនុវត្តកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាកអ្នកផ្តល់(licensor) ឱ្យអ្នកទទួល(licensee)ប្រើប្រាស់សិទ្ធិលើម៉ាកខ្លះៗតាមលក្ខខណ្ឌដែលបានបញ្ជាក់ក្នុងកិច្ចសន្យា។ ដោយមិនអាចផ្ទេរកម្មសិទ្ធិលើម៉ាកទាំងស្រុងឱ្យអ្នកទទួលដូចកិច្ចសន្យាទិញលក់ទេ។ សិទ្ធិដែលបានផ្តល់អាចប្រែប្រួលតាមកិច្ចសន្យារវាងភាគី។

កិច្ចសន្យាទិញលក់ម៉ាក និងកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាក មានភាពខុសគ្នានៃការគិតថ្លៃដែរ។ ជាទូទៅក្នុងកិច្ចសន្យាទិញលក់ភាគីទិញមានកាតព្វកិច្ចប្រគល់លុយជាថ្នូរនឹងវត្ថុដែលបានប្រគល់។ ក្នុងករណីកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាកមានរបៀបប្រគល់ថ្លៃ២យ៉ាងគឺ៖

### កថាខណ្ឌទី១៖ ការទូទាត់សរុប

ទាំងនេះអាចយកទម្រង់បែបបទនៃកិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ ដែលបានបង់ពេញលេញដែលការព្រមព្រៀងមួយដុំត្រូវបានព្រមព្រៀងនិងបង់នៅពេលអាជ្ញាប័ណ្ណត្រូវបានផ្តល់ជូន។

ការទូទាត់សំណងជាដុំក៏អាចត្រូវបានផ្សព្វផ្សាយជាទៀងទាត់ក្នុងរយៈពេលអាជ្ញាប័ណ្ណ។

### កថាខណ្ឌទី២៖ ថ្លៃឈ្នួល

ប្រភេទនៃការពិចារណាធម្មតាបំផុតគឺត្រូវផ្តល់ថ្លៃដើមមួយចំនួនក៏ដូចជាការបង់ថ្លៃសួយសារដែលកំពុងបន្តផ្អែកលើការលក់។ ក្នុងករណីខ្លះថ្លៃឈ្នួលខ្ពស់ត្រូវបានបង់ដូចគ្នានឹងថ្លៃសួយសារ។

នៅពេលដែលប្រាក់កម្រៃដែលត្រូវបង់លើសពីថ្លៃសេវា ដែលត្រូវបង់បន្ទាប់មកថ្លៃឈ្នួលសួយសារត្រូវបង់ជាប្រចាំខែប្រចាំត្រីមាសឬមូលដ្ឋានទូទាត់តាមកាលកំណត់ផ្សេងទៀត។

ចំនួនលាភការបើគិតជាភាគរយអាចប្រែប្រួលពីលិតផលមួយទៅផលិតផលសេវាកម្ម និងទៅសេវាកម្ម និងឧស្សាហកម្មទៅឧស្សាហកម្ម។

លាភការត្រូវបានគណនាតាមអត្រា«មូលដ្ឋាន»ដែលបានកំណត់។ ក្នុងករណីខ្លះនេះអាចជាប្រាក់ចំណេញពីការលក់សុទ្ធ ឬប្រាក់ចំណេញពីការលក់ដុល។ ដូចនេះភាគរយនៃការចំនេញ ទាំងថ្លៃទូទាត់សរុបថ្លៃឈ្នួលពីការទិញលក់អាជ្ញាប័ណ្ណម៉ាកនេះគឺមានលក្ខណៈដូចគ្នាទៅនឹងកិច្ចសន្យាទិញលក់ទូទៅដែរ។

## ផ្នែកទី២៖ ការប្រៀបធៀបកិច្ចសន្យាជួល ម៉ាក និង កិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាក

កិច្ចសន្យាទាំងពីរនេះមានភាពដូចគ្នាគឺ នៅដែលមានពេលវេលាកំណត់ដ៏ច្បាស់លាស់បញ្ជាក់ក្នុងកិច្ចសន្យា។

ភាពខុសគ្នារវាងកិច្ចសន្យាជួល និងកិច្ចសន្យាអាជ្ញាប័ណ្ណគឺជាភាពខុសគ្នារវាងគំនិតច្បាប់ដែលទាក់ទងនឹងកាតព្វកិច្ច និងសិទ្ធិរបស់បុគ្គលម្នាក់ៗនៅក្នុងកិច្ចសន្យា។ កិច្ចសន្យាជួលគឺជាកិច្ចសន្យារវាងភតិកៈ និងភតិបតីដែលផ្ដល់ឱ្យភតិកៈនូវផលប្រយោជន៍ទាំងស្រុងលើទ្រព្យសម្បត្តិ។ ម៉្យាងវិញទៀតអាជ្ញាប័ណ្ណគឺសំដៅលើម្ចាស់ដែលអនុញ្ញាតឱ្យអ្នកមានអាជ្ញាប័ណ្ណធ្វើសកម្មភាពលើទ្រព្យសម្បត្តិរបស់ម្ចាស់។ ភាពខុសគ្នាសំខាន់គឺការជួលផ្ដល់ឱ្យបុគ្គលនូវសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ ខណៈដែលអាជ្ញាប័ណ្ណនោះគឺត្រូវផ្ដល់ឱ្យតែបុគ្គលនូវសិទ្ធិធ្វើសកម្មភាពលើវា។

មានចំណុចដ៏សំខាន់ៗមួយចំនួនដែលកិច្ចសន្យាជួលខុសគ្នាពីកិច្ចសន្យាអាជ្ញាប័ណ្ណ ដែលចំណុចចម្បងទាំងនេះគឺទាក់ទងនឹងបញ្ហានៃការគ្រប់គ្រង។ ជាធម្មតា កិច្ចសន្យាជួលអនុវត្តចំពោះការត្រួតពិនិត្យតិចជាងកិច្ចសន្យាអាជ្ញាប័ណ្ណលើភាគីដែលកំពុងធ្វើការទូទាត់ ឬភាគីទទួល។

កិច្ចសន្យាជួលម៉ាកបង្កើតដើម្បីផលប្រយោជន៍លើម៉ាកដែលពាក់ព័ន្ធ។ ដរាបណាកិច្ចសន្យាជួលម៉ាកមានលក្ខណៈជាអចិន្ត្រៃយ៍ភាគីជួលនៃកិច្ចសន្យាគឺមានសិទ្ធិធ្វើជាម្ចាស់កម្មសិទ្ធិលើម៉ាករួមទាំងសិទ្ធិរក្សា ឬ ក្រុមហ៊ុនណាមួយរួមទាំងម្ចាស់ម៉ាក។ ម៉្យាងវិញទៀតកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកអាចផ្ដល់សិទ្ធិឱ្យភាគីទទួលយកការទូទាត់ ដោយមានការគ្រប់គ្រងកាន់តែច្រើនលើរបៀបប្រើប្រាស់ម៉ាករបស់ពួកគេ។ យោងតាមឧទាហរណ៍ខាងលើកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកមិនអាចត្រូវបានផ្ទេរទៅឱ្យតតីយជនបានទេ ពីព្រោះលក្ខណៈនៃកិច្ចព្រមព្រៀង ឬកិច្ចសន្យាគឺថាភាគីដែលផ្ដល់សិទ្ធិអនុញ្ញាតត្រួតពិនិត្យលើទិដ្ឋភាពជាក់លាក់នៃការប្រព្រឹត្តរបស់អ្នកលើកម្មវត្ថុ។ ការអនុញ្ញាតិឱ្យភាគីផ្សេងទៀតប្រើប្រាស់ម៉ាកជំនួសខ្លួនឯងនឹងជាការរំលោភលើកិច្ចសន្យានោះ។

ដូចនេះកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាកនេះគឺមាននីតិវិធីប្រហាក់ប្រហែលគ្នាទៅនឹង កិច្ចសន្យាជួលទូទៅដែរ។

## ផ្នែកទី៣៖ ករណីសិក្សា

### កថាខណ្ឌទី១៖ អង្គហេតុ

ដើមបណ្តឹងបានដាក់ពាក្យសុំម៉ាកសេវាកម្ម 'msol' ដែលបានកំណត់ប្រភេទលេខ៤១(អាជីវកម្មបោះពុម្ពសៀវភៅអាជីវកម្មសាលារៀនអាជីវកម្មជំនួញសាលា។ល។) នៅថ្ងៃទី២៧ ខែមេសាឆ្នាំ ២០០៧។ ដើមបណ្តឹងគឺជាអ្នកកាន់អាជីវកម្មមួយត្រឹមត្រូវដែល បានចុះបញ្ជីរាល់ម៉ាកសេវាកម្មខាងលើ(តទៅនេះហៅថា"ម៉ាកសេវាកម្ម") ដែលមានលេខចុះបញ្ជី **០១៤៨០៥១** និង **០១៤៨០៥២** ។

ជនជាប់ចោទបានព្រមព្រៀងបើកសាលាឯកជន នៅទីក្រុង **Cheon An** ក្នុងភាពជាដៃគូជាមួយភាគីD ហើយតាមរយៈDដែលស្គាល់ដើមបណ្តឹង ពួកគេបានធ្វើកិច្ចសន្យាប្រើប្រាស់ម៉ាកសេវាកម្ម នៅឆ្នាំ២០០៩ ខែតុលា។ ជនជាប់ចោទបានឱ្យ ១០លានវ៉ុនទៅដើមបណ្តឹងជាថ្លៃសេវាសម្រាប់ការប្រើប្រាស់ម៉ាកសេវាកម្ម តាមកិច្ចសន្យាប្រើប្រាស់ ។

ដើមបណ្តឹងបានបញ្ជូនលិខិតស្នើសុំការហាមឃាត់ប្រើប្រាស់ម៉ាកសេវាកម្មនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ហើយចុងចោទបានឆ្លើយតបនឹងដើមបណ្តឹងនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៦ ថាបានមានការអនុញ្ញាតពីដើមបណ្តឹងឱ្យប្រើប្រាស់ម៉ាកសេវាកម្មដល់ពេលនេះ ហើយចុងចោទបានទទួលយកយោបល់របស់ដើមបណ្តឹង ហើយសន្យាថានឹងចាត់វិធានការជាបន្ទាន់ដើម្បីផ្លាស់ប្តូរវា។

### កថាខណ្ឌទី២៖ ការទាមទារនិងការវិនិច្ឆ័យ

#### ១- ការទាមទាររបស់ភាគី

##### ១.១.) ការទាមទាររបស់ដើមបណ្តឹង

ក្នុងករណីនេះកិច្ចសន្យាសម្រាប់ការប្រើប្រាស់ម៉ាកសេវាកម្ម ត្រូវបានកំណត់ត្រឹមមួយឆ្នាំ ហើយកិច្ចសន្យាថ្មីត្រូវបានចុះហត្ថលេខា ក្នុងគោលបំណងបង្កើនថ្លៃសេវាសម្រាប់បន្តអាជ្ញាប័ណ្ណការប្រើប្រាស់នាថ្ងៃខាងមុខ។ ប៉ុន្តែចុងចោទនៅតែបន្តប្រើប្រាស់ម៉ាកសេវាកម្ម ដោយគ្មានការអនុញ្ញាតឱ្យប្រើប្រាស់ម៉ាកបន្តពីដើមបណ្តឹងដោយសារតែកិច្ចសន្យានោះបានកន្លងផុតទៅរយៈពេលមួយឆ្នាំទៅហើយ។ ដូច្នោះជនជាប់ចោទរួមគ្នាត្រូវសងសម្រាប់ការខូចខាតយោងតាមមាត្រា៦៦ ចំនុច២ នៃច្បាប់ម៉ាកនិង ច្បាប់ស្តីពីការការពារការប្រកួតប្រជែងមិនស្មោះត្រង់និងការការពារការសម្ងាត់ពាណិជ្ជកម្មរបស់ប្រទេសកូរ៉េ។ យោងតាមមាត្រា២និង មាត្រា៥ ក្នុងនាមជាសំណងសម្រាប់ការខូចខាត ហើយតាមមាត្រា៧៥០នៃច្បាប់រដ្ឋប្បវេណីនៃប្រទេសកូរ៉េ ជនជាប់ចោទត្រូវទទួលខុសត្រូវនិង សង១០ លានវ៉ុន សម្រាប់មួយឆ្នាំគិតពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៥ សរុប៥០លានវ៉ុន។

##### ១.២.) ការទាមទាររបស់ចុងចោទ

កិច្ចសន្យានៃការប្រើប្រាស់ម៉ាកនេះ គឺជាកិច្ចសន្យាដែលមិនបានបញ្ជាក់ពីរយៈពេលនៃការប្រើប្រាស់

ដូច្នេះរយៈពេលនៃការប្រើប្រាស់ម៉ាកមិនត្រូវបានកំណត់ត្រឹមមួយឆ្នាំទេ។ ការប្រើប្រាស់របស់ជនជាប់ចោទនៃម៉ាកសេវាកម្ម ចាប់ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៥ ត្រូវបានចាត់ទុកជាត្រឹមត្រូវតាមកិច្ចសន្យាប្រើប្រាស់ម៉ាកនោះ ។

**២- ការវិនិច្ឆ័យ**

១)បញ្ហានៃករណីនេះគឺថាតើជនជាប់ចោទប្រើម៉ាកសេវាកម្មដោយគ្មានការអនុញ្ញាត។ សំខាន់គឺលក្ខណៈនៃកិច្ចសន្យាសម្រាប់ការប្រើប្រាស់ម៉ាក ជាពិសេសរយៈពេលនៃការប្រើប្រាស់ម៉ាក។

២)លក្ខណៈនៃកិច្ចសន្យាសម្រាប់ការប្រើប្រាស់ សរុបទាំងអង្គហេតុខាងលើនិងសក្ខីកម្មរបស់សាក្សីD និងសក្ខីកម្មនិងការទាមទាររបស់ Kim Shin Cheol អាចនឹងត្រូវបានគេទទួលស្គាល់ថា វាជាកិច្ចសន្យានៃការប្រើប្រាស់ដោយគ្មានកាលបរិច្ឆេទផុតកំណត់សម្រាប់ម៉ាកសេវាកម្ម។

- នៅពេលធ្វើកិច្ចសន្យាប្រើប្រាស់ម៉ាកនេះ ដើមបណ្តឹងកំពុងស្ថិតក្រោមការពិនិត្យឡើងវិញដោយមិនបានធ្វើអាជីវកម្ម ពាក់ព័ន្ធនឹងម៉ាក សេវាកម្ម នោះទេ។
- ដើមបណ្តឹងមិនបានផ្តល់ជូនជនជាប់ចោទនូវសំភារៈសំរាប់ប្រតិបត្តិការសាលាទេ។
- លោក Kim Shin Cheol ត្រូវបានបញ្ជាក់ជាថ្មីពីភាគីថាមិនមានពេលវេលាកំណត់សម្រាប់ការប្រើប្រាស់ម៉ាកសេវាកម្ម ទេខណៈពេលទទួលយកភាគហ៊ុនពីD។
- លោក Kim Shin Cheol បានមើលកិច្ចសន្យាដែលបង្ហាញដោយចុងចោទCហើយវារួមបញ្ចូលទាំងថ្លៃសេវា១០លានវ៉ុនសម្រាប់ការប្រើប្រាស់ម៉ាកសេវាកម្ម ហើយវាត្រូវបានកំណត់ត្រឹមទីក្រុង Cheon An ប៉ុន្តែមិនរាប់បញ្ចូលល័ក្ខខ័ណ្ឌនៃការប្រើប្រាស់ឡើយ។
- ដើមបណ្តឹងបានទៅសាលារបស់ជនជាប់ចោទបន្ទាប់ពីបើកសាលា ប៉ុន្តែមិនបានជំទាស់នឹងការប្រើប្រាស់របស់ជនជាប់ចោទនូវម៉ាកសេវាកម្ម ទេ។
- លើសពីនេះទៅទៀតប្រសិនបើកិច្ចសន្យាសម្រាប់ការប្រើប្រាស់ម៉ាក ត្រូវបានកំណត់រយៈពេល ១ ឆ្នាំកិច្ចសន្យាត្រូវបានបញ្ចប់ឬពន្យារបន្ទាប់ពី១ឆ្នាំ ប៉ុន្តែដើមបណ្តឹងបានស្នើសុំឱ្យចុងចោទបញ្ឈប់ការប្រើប្រាស់ម៉ាកសេវាកម្ម តែនៅ ថ្ងៃទី២៤ ខែធ្នូឆ្នាំ ២០១៥ បន្ទាប់ពីរយៈពេល ៦ ឆ្នាំ។

៣) ការបញ្ចប់នៃកិច្ចសន្យា៖ កិច្ចសន្យាដែលបានប្រើប្រាស់នេះ គឺជាកិច្ចសន្យាដែលគេហៅថា contracts innommes ហើយដោយសារសិទ្ធិពាណិជ្ជសញ្ញា គឺជាសិទ្ធិអរូបីយមានភាពខុសគ្នាបន្តិចបន្តួចពីកិច្ចសន្យាជួល ប៉ុន្តែកិច្ចសន្យាទាំងនេះ គឺជាកិច្ចសន្យាដែលបុគ្គលក្រៅពីម្ចាស់ពាណិជ្ជសញ្ញាប្រើប្រាស់ម៉ាកក្នុងវិសាលភាពដែលកំណត់ដោយម្ចាស់។ ហើយកិច្ចសន្យានេះអាចជាកិច្ចសន្យាដែលផ្តល់សិទ្ធិក្នុងការប្រើម៉ាកសម្រាប់ផលិតផលដែលបានកំណត់ ហើយទទួលបាននូវថ្លៃឈ្នួល។ លក្ខណៈរបស់វាគឺស្រដៀងគ្នាជាមួយកិច្ចសន្យាជួល។ ដូច្នេះ

កិច្ចសន្យាសម្រាប់ការប្រើប្រាស់ម៉ាក គឺត្រូវបានអនុវត្តដោយភាពស្រដៀងគ្នាទៅនឹងច្បាប់នៃកិច្ចសន្យាជួល ដែលគ្មានពេលកំណត់ ហើយម្ចាស់ ឬអ្នកជួលអាចជូនដំណឹងអំពីការបញ្ចប់កិច្ចសន្យានៅពេលណាមួយ ហើយការបញ្ចប់មានប្រសិទ្ធិភាពនៅពេលដែលមានរយៈពេលចាប់តាំងពីថ្ងៃដែលភាគីម្ខាងទៀតបានទទួលសេចក្តីជូនដំណឹង។

ដូចដែលបានឃើញក្នុងអង្គហេតុដើមបណ្តឹងបានបញ្ជូនជនជាប់ចោទនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ដោយមានភ័ស្តុតាងនៃខ្លឹមសារស្នើសុំការហាមឃាត់ការប្រើប្រាស់ម៉ាកសេវាកម្ម ហើយចុងចោទដែលបានទទួលវានៅពេលនោះបានទទួលយកយោបល់របស់ដើមបណ្តឹងហើយប្តូរវានៅថ្ងៃទី៣ ខែមីនា ឆ្នាំ ២០១៦ ។ លិខិតស្នើសុំឈប់ប្រើប្រាស់ម៉ាក ត្រូវបានផ្ញើទៅដើមចោទដោយបញ្ជាក់ថាគួរតែចាត់វិធានការ។

ដូច្នេះវាសមហេតុផលក្នុងការសន្មតថាកិច្ចសន្យាសម្រាប់ការប្រើប្រាស់នេះត្រូវ បានបញ្ចប់នៅជុំវិញខែមីនា ឆ្នាំ២០១៦ បន្ទាប់ពីរយៈពេលដ៏សន្ទឹកសន្ធាប់បានកន្លងផុតទៅដោយសារការបញ្ជូនសេចក្តីជូនដំណឹងអំពីការលុបចោលដើមបណ្តឹងនៅថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៥ ។

ដូច្នេះដោយសារជនជាប់ចោទប្រើម៉ាកសេវាកម្ម ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៥ គឺសមហេតុផលដូចកិច្ចសន្យាក្នុងការប្រើប្រាស់នេះទាំងអំណះអំណាងរបស់ភាគីដើមចោទគឺមិនអាចទទួលយកបានទេ។

**៣- សន្និដ្ឋាន**

ដោយយោងតាមការអះអាងទាំងអស់ចំពោះចុងចោទពីដើមចោទ គឺតុលាការបានបណ្តេញចេញពួកគេចេញសាវនការដោយគ្មានមូលហេតុ។ ដោយសារសេចក្តីសម្រេចដំបូងនៃការជំនុំជម្រះមានភាពត្រឹមត្រូវជាមួយនឹងការសន្និដ្ឋាននេះ ហើយការប្តឹងឧទ្ធរណ៍របស់ដើមចោទទាំងអស់នឹងត្រូវបណ្តេញចេញដោយគ្មានហេតុផល[79]។

[79] មជ្ឈមណ្ឌលវវាកម្មអេឡិចត្រូនិច. (២០១៧). *2017나2301.* ដកស្រង់ចេញពី https://patent.scourt.go.kr/ ថ្ងៃទី ២៣ សីហា ឆ្នាំ ២០២០។

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទ ៖ ***របបគតិយុត្តអនុវត្តចំពោះការគ្រប់គ្រងកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក៖*** រួចមកអាចបញ្ជាក់ឱ្យឃើញថាប្រធានបទមួយនេះបានបង្ហាញអំពីតួនាទីយ៉ាងសំខាន់ និងអត្ថប្រយោជន៍ចំពោះសង្គមជាតិកម្ពុជាទាំងមូលតាមរយៈកិច្ចអនុវត្តន៍កម្មសិទ្ធិបញ្ញាកម្ពុជា។

នៅក្នុងវិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជាគឺមានការប្រកួតប្រជែងជាច្រើនទៅលើវិស័យម៉ាកច្រើន ក៏ដូចជាការទិញលក់ម៉ាក និងការជួលម៉ាកហើយការទិញលក់ និងការជួលម៉ាកនេះដែរគឺមានភាពស្មុគស្មាញយ៉ាងខ្លាំងចំពោះច្បាប់ដែលយកមកអនុវត្តចំពោះកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកនេះ ដូចនេះគឺបានជំរុញឱ្យច្បាប់កម្មសិទ្ធិបញ្ញាកម្ពុជាតម្រូវឱ្យមានការតាក់តែងច្បាប់ស្តីពីកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក ថ្វីត្បិតតែច្បាប់កម្ពុជាមិនមានចែងអំពីកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកក៏ពិតមែនតែកម្ពុជាក៏បានចាប់យកវិធាននៃប្បញ្ញត្តិរួមនៃកិច្ចសន្យាទិញលក់ទូទៅ និងកិច្ចសន្យាជួលទូទៅមកអនុវត្តលើកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកនេះតែម្តង គឺដើម្បីងាយស្រួលក្នុងកំណត់យកវិធានច្បាស់លាស់ណាមួយមកអនុវត្តដោយមានប្រសិទ្ធិភាព និងតម្លាភាព និងស្របតាមគោលការណ៍នៃកិច្ចសន្យានៅក្នុងកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកនេះដែរគឺមានការកត់ត្រា ក្នុងគោលបំណងដើម្បីឱ្យកិច្ចសន្យានោះមានប្រសិទ្ធិភាព មានការទុកចិត្ត និងស្របច្បាប់(ទទួលស្គាល់ដោយច្បាប់)។ ម៉្យាងវិញចំពោះការកត់ត្រានេះដែល ក៏តម្រូវឱ្យមានការកែតម្រូវក្នុងលក្ខខណ្ឌឱ្យមួយដែលមន្ត្រីទទួលបន្ទុករកឃើញនូវកំហុសបច្ចេសទេស។ បន្ទាប់ពីបានធ្វើការកត់ត្រានេះបានហើយអ្នកដែលទៅធ្វើការកត់ត្រានោះនឹងទទួលបានសិទ្ធិមួយសម្រាប់ទប់ទល់នឹងការរំលោភបំពាន ឬទង្វើមិនស្របច្បាប់ដែលមាននៅក្នុងច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងការប្រកួតប្រជែងមិនស្មោះត្រង់។

ដូចនេះវិធាននៃបទបញ្ញត្តិរួមនៅក្នុងក្រមរដ្ឋប្បវេណី គឺជារបបគតិយុត្តសម្រាប់យកមកអនុវត្តទៅលើកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក ហើយកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកគឺជាសសៃឈាមយ៉ាងសំខាន់នៅក្នុងវិស័យសេដ្ឋកិច្ច និងក្នុងវិស័យកម្មសិទ្ធិបញ្ញាដែលកក្រសួងពាណិជ្ជកម្មគួរតែយកចិត្តទុកដាក់ឱ្យខ្លាំង ទោលើចំនុចមួយនេះដើម្បីធ្វើឱ្យវិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជាមានភាពរីកចម្រើន និងដើម្បីសេដ្ឋកិច្ចវឌ្ឍនភាពជាតិ។

# អនុសាសន៍

បន្ទាប់ពីធ្វើការស្រាវជ្រាវ លើប្រធានបទ ***របបគតិយុត្តអនុវត្តចំពោះការគ្រប់គ្រងកិច្ចសន្យាអាជ្ញាប័ណ្ណនៃម៉ាក*** រួចមក ការផ្តល់អនុសាស៍មួយចំនួនជាចក្ខុវិស័យ និងយុទ្ធសាស្ត្រទៅថ្ងៃអនាគតដែលជាលទ្ធផលនៃការស្រាវជ្រាវមួយនេះ។

ទោះជាយ៉ាងណាក៏ដោយទាំងកម្ពុជានិងប្រទេសនៅក្នុងសកលលោក គឺមិនមានប្រទេសណាមួយអនុវត្តច្បាប់កម្មសិទ្ធិបញ្ញាឱ្យបាន១០០%ទាំងស្រុងនោះទេ។ ដោយយោងតាមការបកស្រាយទៅលើហេតុផលនឹងទិដ្ឋភាពជាក់ស្តែងនៃផលប្រយោជន៍ និងផលវិបាកតាមរយៈបញ្ហាប្រឈមដោយការរំលោភបំពានសិទ្ធិកម្មសិទ្ធិបញ្ញា មិនមែនមានន័យថាកម្ពុជាយើងគឺអាចទប់ស្កាត់ ឬលុបបំបាត់ទាំងស្រុងនូវអំពើដែលកំពុងកើតឡើងនោះទេ ដោយប្រទេសកម្ពុជាយើងគឺជាប្រទេសដែលកំពុងអភិវឌ្ឍន៍នៅឡើយ។ ដូចនេះ៖

-បើសិនជាច្បាប់ការពារកម្មសិទ្ធិបញ្ញាគឺត្រូវបានរឹតបន្តឹងខ្លាំងពេក គឺប្រជាពលរដ្ឋនឹងមានការខ្វះខាតការងារដោយសារកត្តាជីវភាពរបស់ពួកគេគឺ មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងចំណាយលើផលិតផលរបស់ខ្លួននោះទេ។

-ប្រសិនបើកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកនៅតែមានការរំលោភ និងបំពានដោយគ្មានច្បាប់ការពារឱ្យតឹងរឹងនោះការវិនិយោគវិស័យម៉ាកនៅកម្ពុជានឹងមានភាពចុះខ្សោយ និងមានកាត់បន្ថយពីសំណាក់វិនិយោគទុនមួយចំនួនជាពិសេសនៅឯខាងបរទេស។

-ថ្វីត្បិតតែកម្ពុជាគឺជាប្រទេសដែលកំពុងអភិវឌ្ឍមែនពិត តែកម្ពុជាគួរតែសរសេរពីច្បាប់កិច្ចសន្យាអាជ្ញាប័ណ្ណម៉ាក ដោយមិនចាំបាច់យកវិធាននៃកិច្ចសន្យាទូទៅមកអនុវត្តឡើយព្រោះមើលទៅគឺមានភាពស្មុគស្មាញច្រើន ហើយណាមួយគឺដើម្បីបង្កើនភាពងាយស្រួលដល់អ្នកច្បាប់ និងនិស្សិតសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។

-ប្រសិនបើច្បាប់នៃកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកត្រូវបានបង្កើតឡើងមែននោះ ចូលអ្នកច្បាប់គ្រប់រូបចូលរួមគោរពនិងអនុវត្តតាមឱ្យបានខ្ជាប់ខ្ជួន ក្នុងគោលបំណងដើម្បីឱ្យវិស័យកម្មសិទ្ធិបញ្ញានៅកម្ពុជាមានភាពរីកចម្រើននិងមានប្រសិទ្ធិភាព។

-ប្រសិនបើច្បាប់ស្តីពីកិច្ចសន្យាអាជ្ញាប័ណ្ណម៉ាកនោះបានអនុវត្តឱ្យតឹងរឹងនោះ គឺគ្មានការរំលោភបំពាននិងទង្វើមិនស្របច្បាប់កើតើលកិច្ចសន្យានោះទេ ដូចនេះដំណើរការនៃការធ្វើកិច្ចសន្យាអាជ្ញាប័ណ្ណគឺអាចនឹងប្រព្រឹត្តទៅដោយរលូន។

-ក្រសួងដែលពាក់ព័ន្ធគួរតែសម្រួលដល់ការចុះបញ្ជី និងការកកត់ត្រាកិច្ចសន្យាអាជ្ញាប័ណ្ណធ្វើយ៉ាងណាឱ្យមានភាពរួសរាន់និងរហ័ស ដើម្បីធ្វើឱ្យអាជីវករមួយចំនួននៅកម្ពុជាគឺមានភាពងាយនិងចំនេញពេលវេលាទាំងក្រសួង និងម្ចាស់អាជីកម្ម និងកាន់តែធ្វើឱ្យដំណើរការសេដ្ឋកិច្ចនៅកម្ពុជាមានភាពរីកចម្រើន។

# ឯកសារយោង


## ច្បាប់ និង លិខិតបទដ្ឋានគតិយុត្ត

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧០៤/០០១, ២៤ កញ្ញា ២០០៤។

ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ច្បាប់ភូមិបាល, លេខ នស/០៨០១/១៤, ៣០ សីហា ២០០១។

ច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់, លេខ នស/រកម/០២០២/០០៦, ០៦ ធ្នូ ២០០១។

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី,លេខ នស/រកម/១៥១១/០០៧, ០៩ ឧសភា ២០១១។

ប្រកាសស្តីពីការកត់ត្រា និងកិច្ចសន្យាអាជ្ញាប័ណ្ណចំពោះម៉ាក និងកិច្ចសន្យាផ្តល់សិទ្ធិប្រកបអាជីវកម្ម ២០២០។

ប្រកាសរួមស្តីពីការផ្តល់សេវាសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម, លេខ១២១៧, ២៧ វិច្ឆិកា ២០១៧។

## សៀវភៅ

នី វិចិត្រ. ២០១៣ *នីតិកម្មសិទ្ធិបញ្ញាកម្ពុជា* (បោះពុម្ពលើកទី១, ២០១៣)។

លី កុសល, *លក្ខខណ្ឌនៃការបង្កើតកិច្ចសន្យា* (ឯកសារថតចម្លង, ២០១៨)។

យស បានចំរុង និងខាំ សុមករា, *នីតិកិច្ចសន្យាពិសេស* (ឯកសារថតចម្លង, ២០១៣)។

## គេហទំព័រ

https://www.wipo.int/patentscope/en/

**http://www.moc.gov.kh/en-us/**

ដកស្រង់ចេញពី https://patent.scourt.go.kr/, *2017ㄴ/2301*. ២០១៧។

# ឧបសម្ព័ន្ធ

# រដ្ឋធម្មនុញ្ញ

# នៃព្រះរាជាណាចក្រ

# កម្ពុជា

# ១៩៩៣

**មាត្រា ៣៥..**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និង ដោះស្រាយយ៉ាងហ្មត់ចត់ពីរដ្ឋការរដ្ឋ ។

**មាត្រា ៣៦..**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្រប តាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា ។

ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកម្រៃ ដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និង ចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និង ការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ក្នុងច្បាប់ ។

# ក្រមរដ្ឋប្បវេណី
# នៃព្រះរាជាណាចក្រ
# កម្ពុជា
# ២០០៧

## សន្ធានុក្រមក្រមរដ្ឋប្បវេណី

**កិច្ចសន្យា** គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នា ព្រមបង្កើតកែប្រែ រលត់កាតព្វកិច្ច។

### ផ្នែកទី ៤

### សមត្ថភាពក្នុងការធ្វើសកម្មភាព

**មាត្រា ១៦.** អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនដែលត្រូវបានកម្រិតសមត្ថភាពសំដៅទៅលើអនីតិជនជននៅក្រោមអាណាព្យាបាលទូទៅនិងជននៅក្រោមហិតូបត្ថម្ភ។

### កថាភាគទី ១

**មាត្រា ២២.** អនុភាពនៃអត្តាធីនភាព

អនីតិជនដែលទទួលអត្តាធីនភាពត្រូវបានចាត់ទុកថាបានដល់នីតិភាព។

### ជំពូកទី ៤

### សិទ្ធិជួលអចិន្ត្រៃយ៍

**មាត្រា ២៤៥.** ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍

១.សិទ្ធិជួលអចិន្ត្រៃយ៍ពុំមានអានុភាពឡើយបើមិនបានបង្កើតឡើងជាលាយល័ក្ខណ៍អក្សរ។

២.សិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានបង្កើតឡើងដោយពុំបានធ្វើជាលាយល័ក្ខណ៍អក្សរត្រូវចាត់ទុកថាជាភតិសន្យាដែលពុំមានកំណត់អំឡុងពេលហើយអាចត្រូវបានបញ្ឈប់ដោយភាគីម្ខាងនៅពេលណាក៏បានដោយផ្អែកតាមបញ្ញត្តិនៃមាត្រា៦១៥(ការស្នើសុំឱ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល) នៃក្រមនេះ។

### ផ្នែកទី ២

### វិការៈក្នុងការបង្ហាញឆន្ទៈ និង សុពលភាពនៃកិច្ចសន្យា

**មាត្រា ៣៤៥.** ការបង្ហាញឆន្ទៈដែលមានវិការៈ

អ្នកដែលបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈតាមបញ្ញត្តិនៃផ្នែកទី២(វិការៈក្នុងការបង្ហាញឆន្ទៈនិងសុពលភាពនៃកិច្ចសន្យា)នេះនិងផ្នែកទី៣ (មោឃភាព និង ការលុបចោល) ក្នុងករណីដូចខាងក្រោមនេះ៖

ក.ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការភាន់ច្រឡំ។

ខ.ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយការឆបោកឬការគម្រាមកំហែងឬការបង្ហាញការមិនពិតរបស់ភាគីម្ខាងទៀត។

គ.ការបង្ហាញឆន្ទៈត្រូវបានធ្វើឡើងដោយអំពើឆ្លៀតឱកាសដោយមានគោលបំណងកេងយកចំណេញហួសហេតុ។

**មាត្រា ៣៤៦.** ការភាន់ច្រឡំ

១.ក្នុងករណីដែលភាគីមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យាបើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីការភាន់ច្រឡំនេះភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថាការបង្ហាញនោះមានវិការៈ។

២.ក្នុងករណីដែលភាគីម្ខាងនៃកិច្ចសន្យាមានការភាន់ច្រឡំអំពីចំណុចនៃកិច្ចសន្យាដែលខ្លួនយល់ឃើញថាសំខាន់ឬចំណុចដែលខ្លួនយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យាបើភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងអំពីភាពសំខាន់នៃចំណុចនេះនិងការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈនោះភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

៣.ក្នុងករណីដែលភាគីទាំងសងខាងមានការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យាឬចំណុចនៃកិច្ចសន្យាដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ឬចំណុចដែលភាគីទាំងសងខាងយល់ឃើញថាសំខាន់ក្នុងការបង្កើតកិច្ចសន្យាទោះបីជាភាគីម្ខាងមិនមានលទ្ធភាពអាចដឹងអំពីការភាន់ច្រឡំរបស់ភាគីម្ខាងទៀតក៏ដោយក៏ភាគីដែលបានភាន់ច្រឡំអាចលុបចោលនូវកិច្ចសន្យាបានដែរដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

៤.ការលុបចោលនូវកិច្ចសន្យាដោយការភាន់ច្រឡំក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន។ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិតហើយគ្មានកំហុសអំពីការភាន់ច្រឡំមិនអាចអះអាងនូវការលុបចោលចំពោះតតិយជននោះបានឡើយ។

**មាត្រា ៣៤៧.** ការឆបោក

១.បុគ្គលដែលបានធ្វើការបង្ហាញឆន្ទៈដោយសារការឆបោករបស់ភាគីម្ខាងទៀតអាចលុបចោលនូវកិច្ចសន្យាដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

២.ក្នុងករណីដែលការបង្ហាញឆន្ទៈបានធ្វើឡើងដោយសារការឆបោករបស់តតិយជនអ្នកបង្ហាញឆន្ទៈអាចលុបចោលនូវកិច្ចសន្យាដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈលុះត្រាតែក្នុងករណីដែលភាគីម្ខាងទៀតនៃការបង្ហាញឆន្ទៈនោះបានដឹងឬអាចដឹងអំពីការឆបោកនោះ។

៣.ការលុបចោលនូវកិច្ចសន្យាដោយការឆបោកក្រៅពីភាគីម្ខាងទៀតអាចអះអាងចំពោះតតិយជនបាន។ប៉ុន្តែប្រសិនបើតតិយជនជាជនសុចរិតហើយគ្មានកំហុសអំពីការឆបោកមិនអាចអះអាងនូវអានុភាពនៃការលុបចោលចំពោះតតិយជននោះបានឡើយ។

**មាត្រា ៣៥១.** អំពើកេងយកចំណេញហួសហេតុ

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យាដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ចឬភាពល្ងង់ឬការខ្វះការពិសោធន៍ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបានដោយហេតុថាការបង្ហាញឆន្ទៈនោះមានវិការៈ។

## ជំពូកទី ១

## ការលក់ទិញ

### ផ្នែកទី ១

### លក្ខណៈនៃការលក់ និង ការបង្កើតកិច្ចសន្យាលក់ទិញ

**មាត្រា ៥២១.** ថ្លៃលក់ទិញ

១.ភាគីនៃកិច្ចសន្យាត្រូវកំណត់ចំនួនប្រាក់នៃថ្លៃលក់ទិញឬវិធីកំណត់ចំនួនប្រាក់នោះនៅក្នុងកិច្ចសន្យា។

២.ចំនួនប្រាក់នៃថ្លៃលក់ទិញអាចត្រូវបានកំណត់ដោយយោលទៅតាមតម្លៃនៃទំនិញណាមួយនៅទីផ្សារក្នុងពេលបច្ចុប្បន្នឬអនាគតឬដោយផ្អែកលើការវាយតម្លៃដែលធ្វើដោយតតិយជនដែលត្រូវបានជ្រើសរើសតាមរបៀបកំណត់ដោយគូភាគី។ក្នុងករណីដែលការវាយតម្លៃរបស់តតិយជនត្រូវបានធ្វើឡើងដោយភាន់ច្រឡំឬករណីដែលការវាយតម្លៃនោះច្បាស់ជាផ្ទុយនឹងសមភាពភាគីនៃកិច្ចសន្យាដែលទទួលការខូចខាតផលប្រយោជន៍របស់ខ្លួនដោយសារការវាយតម្លៃនោះអាចតវ៉ាចំពោះការវាយតម្លៃនោះបាន។

៣.ភាគីនៃកិច្ចសន្យាអាចកំណត់ចំនួនថ្លៃលក់ទិញដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដឬដោយឱ្យអ្នកទិញបង់ធនលាភដែលមិនកំណត់ពេលឬធនលាភមួយជីវិតបាន។ប៉ុន្តែក្នុងករណីដែលតតិយជនវាយតម្លៃដោយយោលទៅតាមបញ្ញត្តិនៃកថាខណ្ឌទី២ខាងលើនេះថ្លៃលក់ទិញត្រូវបាន

កំណត់ដោយបង្ហាញចំនួនថ្លៃដើមពិតប្រាកដលើកលែងតែករណីដែលគូភាគីប្រគល់សិទ្ធិទៅតតិយជនដោយជាក់លាក់។

**មាត្រា ៥២៥.** បុគ្គលដែលមិនអាចក្លាយជាអ្នកទិញបាន (មួយ)

១.អ្នកគ្រប់គ្រងទ្រព្យសម្បត្តិតាមច្បាប់តាមផ្លូវតុលាការឬតាមកិច្ចសន្យាមិនអាចក្លាយជាអ្នកទិញឬជាអ្នកទិញដោយការលក់ដោយបង្ខំនូវទ្រព្យសម្បត្តិដែលខ្លួនបានទទួលភារកិច្ចលក់ដោយផ្ទាល់ខ្លួនឬតាមរយៈអន្តរការីបានឡើយ។

២.បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះមន្ត្រីរាជការដែលទទួលបន្ទុកចាត់ការការលក់ដោយបង្ខំឬទទួលបន្ទុកគ្រប់គ្រងការលក់ដោយបង្ខំ។

៣.ចំពោះការលក់ទិញដែលផ្ទុយនឹងកថាខណ្ឌទី១ឬទី២ខាងលើនេះមានតែកម្មសិទ្ធិករនៃវត្ថុមុនពេលលក់ឬសន្តតិជនឬប្រតិសិទ្ធិរបស់កម្មសិទ្ធិករនោះទេទើបអាចលុបចោលកិច្ចសន្យានេះបាន។

## ជំពូកទី ៥

## ភតិសន្យា

### ផ្នែកទី ១

### បទបញ្ញត្តិទូទៅ

**មាត្រា ៥៩៦.** និយមន័យភតិសន្យា

១.ភតិសន្យាសំដៅទៅលើកិច្ចសន្យាមួយដែលភាគីម្ខាងឱ្យភាគីម្ខាងទៀតប្រើប្រាស់និងអាស្រ័យផល ពីវត្ថុណាមួយដោយយកថ្លៃ។

២.វត្ថុដែលជាកម្មវត្ថុនៃភតិសន្យាមានចលនវត្ថុនេងអចលនវត្ថុ។

# ច្បាប់

# ស្តីពី

# ការអនុវត្តក្រមរដ្ឋប្បវេណី

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## មាត្រា ៩.- អត្ថន័យនៃលិខិតយថាភូត

"លិខិតយថាភូត" ដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតខាងក្រោម :

ក-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្វីការ) មាត្រា ៥១៦ (ការបង្កើតកិច្ចសន្យាលក់ទិញ) និង មាត្រា ៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវធ្វើឡើងដោយសារការី ឬ លិខិតឯកជនដែលសារការីចុះនិទ្ទេសថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ និងចុះកាលបរិច្ឆេទ និងហត្ថលេខាក្រោយពេលខ្លួនបញ្ជាក់ថា លិខិតនោះមានភាពត្រឹមត្រូវតាមច្បាប់ ។ ប៉ុន្តែ ចំពោះលិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៣៣៦ (ការបង្កើតកិច្ចសន្យាដោយសំណើ និងស្វីការ) និងមាត្រា៨៦២ (អានុភាពនៃការចាត់ចែងហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី លិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើង ដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជីក៏ជាលិខិតយថាភូតដែរ ។

ខ-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ៨៤៥ (ការតតាំងនៃហ៊ីប៉ូតែក) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី ។



គ-លិខិតយថាភូតដែលកំណត់ក្នុងមាត្រា ១១៧២ (បុគ្គលដែលមិនអាចក្លាយជាសាក្សីជាអាទិ៍) មាត្រា ១១៧៣ (មរតកសាសន៍ដោយលិខិតយថាភូត) និង មាត្រា ១១៨១ (បទប្បញ្ញត្តិពិសេសចំពោះមរតកសាសន៍របស់ជនជាតិខ្មែរដែលរស់នៅបរទេស) នៃក្រមរដ្ឋប្បវេណី សំដៅទៅលើលិខិតដែលត្រូវបានធ្វើឡើងដោយសារការី ឬ តង់ស៊ីលតាមបញ្ញត្តិនៃមាត្រានីមួយៗ ខាងលើនេះ ។

# ច្បាប់

# ភូមិបាល

## ផ្នែកទី ៤ : អំពីការជួលអចលនវត្ថុ

**មាត្រា ១០៦.-**

កម្មសិទ្ធិករនៃទ្រព្យជាអចលនវត្ថុអាចជួលទ្រព្យរបស់ខ្លួនឱ្យអ្នកដទៃបាន ។ ការជួល ជាកិច្ចសន្យាដែលកម្មសិទ្ធិករនៃទ្រព្យមួយប្រគល់ទ្រព្យនោះឱ្យជនណាម្នាក់ប្រើប្រាស់ក្នុងរយៈពេលមួយ ដោយយកជាប្រាក់ឈ្នួលមកវិញយ៉ាងទៀងទាត់តាមសមាមាត្រនៃរយៈពេលប្រើប្រាស់ ។ កិច្ចសន្យានៃការជួលអចលនវត្ថុហៅថាភតិសន្យា ។

